# សេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធី "Notice of Procedural Safeguards"

សិទ្ធិ អប់រំពិសេស របស់មាតាបិតា និងកុមារ "Special Education Rights of Parents and Children" ស្ថិតក្រោម ច្បាប់ស្តីពីការអប់រំជនពិការ "Individuals with Disabilities Education Act" ផ្នែក B និងច្បាប់អប់រំ រដ្ឋកាលីហ្វ័រញ៉ា "California Education Code"។

## បានពិនិត្យកែប្រែឡើងវិញ នៅខែមីនា ឆ្នាំ 2024

ចំណាំ៖ ពាក្យថា “មណ្ឌលសិក្សាធិការ” ត្រូវបានប្រើប្រាស់ក្នុងឯកសារនេះគ្រប់ទីកន្លែង ដើម្បីពិពណ៌នា ពីភ្នាក់ងារអប់រំរដ្ឋណាមួយ ដែលទទួលខុសត្រូវក្នុងការផ្តល់កម្មវិធីអប់រំពិសេស "special education program" ដល់កូនៗ របស់អ្នក។ ពាក្យ "វាយតម្លៃ" ត្រូវបានប្រើប្រាស់ ដោយមានន័យថា ការវាយតម្លៃ ឬការធ្វើតេស្ត។ ច្បាប់សហព័ន្ធ និងរដ្ឋ ត្រូវបានលើកឡើង គ្រប់ទីកន្លែង នៅក្នុងសេចក្តីជូនដំណឹងនេះ ដោយប្រើអក្សរកាត់ជាភាសាអង់គ្លេស ដែលនឹងមានពន្យល់បន្ថែម នៅក្នុងសទ្ទានុក្រម នៅចុងបញ្ចប់នៃ សេចក្តីជូនដំណឹងនេះ។

### តើ សេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធី ជាអ្វី?

ព័ត៌មាននេះ នឹងផ្តល់ជូនអ្នក ក្នុងនាមជា ឪពុកម្តាយ អាណាព្យាបាលស្របច្បាប់ និងជាឪពុកម្តាយជំនួស របស់សិស្សដែលមានពិការភាព ចាប់ពីអាយុ 3 ឆ្នាំ ដល់អាយុ 21 ឆ្នាំ និងសិស្សានុសិស្សដែលឈានចូលអាយុ 18 ឆ្នាំ ដែលជាអាយុនីតិភាពពីទិដ្ឋភាពទូទៅនៃសិទ្ធិអប់រំ ឬការការពារតាមនីវិធី របស់អ្នក។

សេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធី "The Notice of Procedural Safeguards" គឺតម្រូវឱ្យធ្វើឡើង ស្ថិតក្រោម ច្បាប់ស្តីពីការអប់រំជនពិការ "Individuals with Disabilities Education Act" (IDEA) ហើយសេចក្តីជូនដំណឹងនេះ ត្រូវតែផ្តល់ជូនអ្នក៖

- ម្តងក្នុងមួយឆ្នាំសិក្សា
- នៅពេលណាដែលអ្នកសុំច្បាប់ចម្លង
- នៅពេលដែលកូនរបស់អ្នកត្រូវបានបញ្ជូនទៅ ធ្វើការវាយតម្លៃ សម្រាប់ ការអប់រំពិសេស ជាលើកដំបូង
- នៅគ្រប់ពេលដែលអ្នកត្រូវបានផ្តល់ជូនផែនការវាយតម្លៃ ដើម្បីធ្វើការវាយតម្លៃកូនរបស់អ្នក

- នៅពេលដែលអ្នកទទួលបានពាក្យបណ្តឹងពីរដ្ឋដំបូង ឬដំណើរការពាក្យបណ្តឹងតាមនីតិវិធី ក្នុងឆ្នាំសិក្សា និង
- នៅពេលដែលការសម្រេចចិត្តត្រូវបានធ្វើឡើង ដើម្បីធ្វើការផ្លាស់ទីកុមារពិការទៅសាលារៀនផ្សេង ដែលជាការផ្លាស់ប្តូរកន្លែងសិក្សាថ្មីសម្រាប់ពួកគេ

ច្បាប់ចម្លងអេឡិចត្រូនិក នៃសេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធី "Notice of Procedural Safeguards" អាចរកបាននៅ ក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា "California Department of Education" (CDE) និងគេហទំព័រ ភាពជាដៃគូ និងការចូលរួមរបស់គ្រួសារ សម្រាប់ការអប់រំពិសេស "Special Education Family Involvement & Partnerships" តាម https://www.cde.ca.gov/sp/se/fp/។

(20 *ច្បាប់សហរដ្ឋអាមេរិក "United States Code"* [*USC*] ផ្នែក 1415 [d]; 34 *ច្បាប់នៃបទប្បញ្ញត្តិសហព័ន្ធ "Code of Federal Regulations"* [*CFR*] ផ្នែក 300.504; ច្បាប់អប់រំរដ្ឋកាលីហ្វ័រញ៉ា "California *Education Code"* [*EC*] ផ្នែក 56301 [d] [2], *EC* ផ្នែក 56321, និង *EC* ផ្នែក 56341.1 [g] [1])

# តារាងមាតិកា

សេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធី "Notice of Procedural Safeguards" ..................... 1
បានពិនិត្យកែប្រែឡើងវិញ នៅខែមីនា ឆ្នាំ 2024 ..................... 1
តើសេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធីជាអ្វី? ..................... 1
តើ IDEA ជាអ្វី? ..................... 5
តើខ្ញុំអាចចូលរួមក្នុងការសម្រេចចិត្តលើការអប់រំរបស់កូនខ្ញុំបានដែរឬទេ? ..................... 5
តើខ្ញុំអាចទទួលបានជំនួយបន្ថែមពីកន្លែងណាដែរ? ..................... 6
ចុះបើកូនខ្ញុំ ថ្លង់ ពិបាកស្តាប់ ពិការភ្នែក ពិបាកមើល ឬថ្លង់ផង ពិការភ្នែកផង? ..................... 6
ការជូនដំណឹង ការយល់ព្រម ការវាយតម្លៃ ការតែងតាំងមាតាបិតាជំនួស និងការចូលទៅប្រើប្រាស់កំណត់ត្រានានា ..................... 7
សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ..................... 7
ការយល់ព្រមពីឪពុកម្តាយសិស្ស ..................... 8
ការតែងតាំង មាតាបិតាជំនួសរបស់សិស្ស ..................... 11
ការវាយតម្លៃទៅលើការមិនរើសអើង ..................... **Error! Bookmark not defined.**
ការវាយតម្លៃឯករាជ្យ សម្រាប់ការអប់រំ ..................... 12
ការចូលទៅប្រើប្រាស់ កំណត់ត្រាអប់រំ ..................... 13
របៀបដោះស្រាយវិវាទ ..................... 13
ដំណើរការសវនាការតាមនីតិវិធីកំណត់ ..................... 13
ការនាំសម្រុះសម្រួល និងជម្រើស ដំណោះស្រាយវិវាទផ្សេង ..................... 14
សិទ្ធិដំណើរការនីតិវិធីតាមការកំណត់ ..................... 15
ការដាក់ពាក្យបណ្តឹងដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ ..................... 16
វិន័យសាលារៀន និងនិតិវិធីនៃការដាក់សិស្សពិការចូលរៀន ..................... 20
វិន័យសាលារៀន និងការកំណត់ការអប់រំជំនួសបណ្តោះអាសន្ន ..................... 20
សិស្សដែលចូលរៀននៅសាលាឯកជន ..................... 22
នីតិវិធីបណ្តឹងរដ្ឋ ..................... 24
ការជួយគាំទ្រដល់គ្រួសារ ..................... 25
ច្បាប់ព្រឹទ្ធសភាលេខ 511 មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាចគ្រួសារ ..................... 25

សទ្ទានុក្រមនៃអក្សរកាត់ដែលប្រើនៅក្នុងសេចក្តីជូនដំណឹងនេះ .......................................... 37

## តើ IDEA ជាអ្វី?

IDEA គឺជាច្បាប់សហព័ន្ធដែលតម្រូវឱ្យមណ្ឌលសិក្សាធិការផ្តល់នូវ "ការអប់រំសមស្របសម្រាប់គ្រប់គ្នា ដោយឥតគិតថ្លៃ" free appropriate public education (FAPE) ដល់កុមារពិការភាពដែលមានសិទ្ធិទទួលបាន។ ការអប់សមស្របសម្រាប់គ្រប់គ្នា ដោយឥតគិតថ្លៃ "free appropriate public education" (FAPE) មានន័យថា ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានា ដែលត្រូវបានផ្តល់ជូន ដូចបានពិពណ៌នានៅក្នុង កម្មវិធីអប់រំជាបុគ្គល "individualized education program" (IEP) និងស្ថិតក្រោមការត្រួតពិនិត្យដោយរដ្ឋចំពោះកូនរបស់អ្នក ដោយឥតគិតថ្លៃ។

## តើខ្ញុំអាចចូលរួមក្នុងការសម្រេចចិត្តលើការអប់រំរបស់កូនខ្ញុំបានដែរឬទេ?

អ្នកត្រូវតែទទួលបាននូវឱកាសក្នុងការចូលរួម កិច្ចប្រជុំដើម្បីធ្វើការសម្រេចចិត្តណាមួយ ទាក់ទងនឹងកម្មវិធីអប់រំពិសេស "special education program" របស់កូនអ្នក។ អ្នកមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំក្រុមការងារ កម្មវិធី IEP លើការកំណត់អត្តសញ្ញាណ (សិទ្ធិទទួលបាន) ការវាយតម្លៃ ឬការដាក់ចូលថ្នាក់សិក្សា សម្រាប់កូនអ្នក និងបញ្ហាផ្សេងទៀតដែលទាក់ទងនឹង FAPE ដល់កូនអ្នក។ (20 *USC* ផ្នែក 1414 [d] [1] B– [d] [1] [D]; 34 *CFR* ផ្នែក 300.321; ផ្នែក *EC* 56341 [b] និង *EC* ផ្នែក 56343 [c])

មាតាបិតា ឬអាណាព្យាបាល និងភ្នាក់ងារអប់រំក្នុងមូលដ្ឋាន "local educational agency" (LEA) មានសិទ្ធិចូលរួមក្នុងការអភិវឌ្ឍន៍ កម្មវិធី IEP និងបង្ហាញពីបំណងរបស់ពួកគេ ក្នុងការថតសំឡេងតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងដំណើរការនៃកិច្ចប្រជុំក្រុមការងារ កម្មវិធី IEP។ យ៉ាងតិចណាស់ 24 ម៉ោងមុនពេលកិច្ចប្រជុំ មាតាបិតា ឬអាណាព្យាបាលសិស្សត្រូវជូនដំណឹងដល់សមាជិក ក្រុមការងារ កម្មវិធី IEP ពីបំណងរបស់ពួកគេក្នុងការថតកិច្ចប្រជុំ។ ប្រសិនបើមាតាបិតា ឬអាណាព្យាបាលសិស្ស មិនយល់ស្របជាមួយ LEA ក្នុងការប្រើឧបករណ៍ថតសំឡេងនៅពេលប្រជុំ កម្មវិធី IEP ទេ នោះកិច្ចប្រជុំ នឹងមិនត្រូវបានថតសំឡេង ដោយឧបករណ៍ថតសំឡេងឡើយ។

សិទ្ធិរបស់អ្នក រួមមាន ការទទួលបាននូវព័ត៌មានពីកម្មវិធី FAPE រួមទាំង ជម្រើសនានាទៅលើកម្មវិធីសិក្សា និងជម្រើសកម្មវិធីសិក្សាដែលមានស្រាប់ទាំងអស់ ទាំងកម្មវិធីសិក្សារដ្ឋ និងកម្មវិធីសិក្សាឯកជន។ (20 *USC* ផ្នែក 1401 [3] និង 1412 [a] [3]; 34 *CFR* ផ្នែក 300.111; ផ្នែក *EC* 56301, 56341.1 [g] [1] និង 56506)

## តើខ្ញុំអាចទទួលបានជំនួយបន្ថែមពីកន្លែងណាដែរ?

នៅពេលដែលអ្នកមានការព្រួយបារម្ភ ពីការអប់រំរបស់កូនអ្នក វាជារឿងចាំបាច់ណាស់ដែលអ្នកត្រូវទាក់ទងទៅកាន់ លោកគ្រូ-អ្នកគ្រូ ឬអ្នកគ្រប់គ្រងកូនរបស់អ្នក ដើម្បីពិភាក្សា ពីកូនរបស់អ្នក និងបញ្ហាផ្សេងៗទៀតដែលអ្នកមើលឃើញ។ បុគ្គលិកសិក្សា បម្រើការងារនៅក្នុងមណ្ឌលសិក្សាធិការរបស់អ្នក ឬតាមតំបន់ផែនការអប់រំពិសេសក្នុងមូលដ្ឋាន "special education local plan area" (SELPA) អាចឆ្លើយសំណួរផ្សេងៗ ពីការអប់រំរបស់កូនអ្នក សិទ្ធិរបស់អ្នក និងការការពារតាមនីតិវិធី។ លើសពីនេះទៀត នៅពេលដែលអ្នកមានការព្រួយបារម្ភ ការសន្ទនាក្រៅផ្លូវការនេះ ច្រើនតែជួយដោះស្រាយបញ្ហា និងជួយរក្សាការទំនាក់ទំនងដោយបើកចំហ។

អ្នកក៏អាចទាក់ទងទៅកាន់អង្គការមាតាបិតាមួយ ក្នុងចំណោមអង្គការជាច្រើនទៀត នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ដូចជា មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាចគ្រួសារស្តីពីពិការភាព "Family Empowerment Centers on Disability" (FECs) ឬមជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មានមាតាបិតាសិស្ស "Parent Training and Information Centers" (PTICs) ដែលមានទីតាំងនៅពាសពេញរដ្ឋ។ អង្គការទាំងអស់នេះ ត្រូវបានបង្កើតឡើង ដើម្បីបង្កើនកិច្ចសហការ រវាងមាតាបិតាសិស្ស និងអ្នកអប់រំ ដើម្បីកែលម្អប្រព័ន្ធអប់រំ និងដើម្បីផ្តល់ព័ត៌មាន ការបណ្តុះបណ្តាល និងធនធានបន្ថែមនានា សម្រាប់គ្រួសាររបស់សិស្សានុសិស្ស និងយុវជន ដែលមានពិការភាព។ ព័ត៌មានទំនាក់ទំនង ទៅកាន់អង្គការទាំងនេះ អាចរកបាននៅលើគេហទំព័រ CDE, និង អង្គការមាតាបិតា សម្រាប់ការអប់រំពិសេស រដ្ឋកាលីហ្វ័រញ៉ា "Special Education California Parent Organizations" នៅ https://www.cde.ca.gov/sp/se/qa/caprntorg.asp។

ធនធានបន្ថែម ត្រូវបានរាយបញ្ជីនៅចុងបញ្ចប់នៃឯកសារនេះ ដើម្បីជួយអ្នកឱ្យយល់បន្ថែម ពីការការពារតាមនីតិវិធី។

## ចុះបើកូនខ្ញុំ ថ្លង់ ពិបាកស្តាប់ ពិការភ្នែក ពិបាកមើល ឬថ្លង់ផងពិការភ្នែកផង?

សាលាអប់រំពិសេសរបស់រដ្ឋ "State Special Schools" ផ្តល់សេវាកម្មដល់សិស្សានុសិស្សដែល ថ្លង់ ពិបាកស្តាប់ ពិការភ្នែក ពិបាកមើល ឬថ្លង់ផងពិការភ្នែកផង នៅទីតាំងទាំងបីរបស់ខ្លួនរួមមាន៖ សាលាកាលីហ្វ័រញ៉ាសម្រាប់មនុស្សថ្លង់ "California Schools for the Deaf" នៅទីក្រុង Fremont និងទីក្រុង Riverside និងសាលាកាលីហ្វ័រញ៉ាសម្រាប់ជនពិការភ្នែក "California School for the Blind" នៅទីក្រុង Fremont។ កម្មវិធីសាលាសម្រាប់ការស្នាក់នៅ និងការអប់រំប្រចាំថ្ងៃ "Residential and day school programs"

ត្រូវបានផ្តល់ជូនដល់សិស្សានុសិស្សចាប់ពីទារករហូតដល់អាយុ 21 ឆ្នាំ នៅសាលារដ្ឋសម្រាប់មនុស្សថ្លង់ "State Schools for the Deaf" ទាំងពីរទីតាំង។ កម្មវិធីនេះត្រូវបានផ្តល់ជូនដល់សិស្សានុសិស្ស ដែលមានអាយុចាប់ពី 5 ឆ្នាំ ទៅ 21 ឆ្នាំ នៅសាលាកាលីហ្វ័រញ៉ាសម្រាប់ជនពិការភ្នែក "California School for the Blind"។ សាលាអប់រំពិសេសរបស់រដ្ឋ "State Special Schools" ក៏ផ្តល់សេវាកម្មវាយតម្លៃ និងជំនួយបច្ចេកទេសផងដែរ។ សម្រាប់ព័ត៌មានបន្ថែម ពីសាលាអប់រំពិសេសរបស់រដ្ឋ "State Special Schools" សូមចូលទៅកាន់គេហទំព័រ CDE, និង សាលាអប់រំពិសេសរបស់រដ្ឋ "State Special Schools" នៅ https://www.cde.ca.gov/sp/ss/index.asp ឬសាកសួរព័ត៌មានបន្ថែមពីសមាជិកក្រុមការងារ កម្មវិធី IEP កូន របស់អ្នក។

## ការជូនដំណឹង ការយល់ព្រម ការវាយតម្លៃ ការតែងតាំងមាតាបិតាជំនួស និងការចូលទៅប្រើប្រាស់កំណត់ត្រានានា

### សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន

### នៅពេលណាត្រូវការការជូនដំណឹង?

ការជូនដំណឹងនេះត្រូវតែផ្តល់ឱ្យនៅពេលដែលមានការស្នើសុំពីមណ្ឌលសិក្សាធិការ ឬមានការបដិសេធទៅលើគំនិតផ្តួចផ្តើមការផ្លាស់ប្តូរ ក្នុងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ឬកន្លែងអប់រំ សម្រាប់កូនរបស់អ្នកដែលមានតម្រូវការពិសេស ឬការផ្តល់ជូន កម្មវិធី FAPE (20 *USC* ផ្នែក 1415 [b] [3] និង (4), 1415 [c] [1], និង 1414 [b] [1]; 34 *CFR* ផ្នែក 300.503; ផ្នែក *EC* 56329 និង 56506 [a])

មណ្ឌលសិក្សាធិការត្រូវជូនដំណឹងដល់អ្នក ពីការវាយតម្លៃដែលបានស្នើសុំឡើងពីកូនរបស់អ្នកជាលាយលក្ខណ៍អក្សរ ឬផែនការវាយតម្លៃក្នុងរយៈពេល 15 ថ្ងៃបន្ទាប់ពីការស្នើសុំការវាយតម្លៃជាលាយលក្ខណ៍អក្សររបស់អ្នក។ សេចក្តីជូនដំណឹងត្រូវតែច្បាស់ងាយយល់ និងធ្វើឡើងជាភាសាកំណើតរបស់អ្នក ឬតាមវិធីទំនាក់ទំនងផ្សេងទៀត លុះត្រាតែមិនមានលទ្ធភាពធ្វើទៅតាមវិធីទាំងនោះបានទេ។ (34 *CFR* ផ្នែក 300.304; ផ្នែក *EC* 56321)

### តើសេចក្តីជូនដំណឹងនឹងប្រាប់ខ្ញុំពីអ្វីខ្លះ?

សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនត្រូវតែរួមបញ្ចូលចំណុចខាងក្រោម៖

1. ការពិពណ៌នាពីសកម្មភាពនានាដែលបានស្នើសុំឡើង ឬបដិសេធដោយមណ្ឌលសិក្សាធិការ
2. ការពន្យល់ ពីមូលហេតុដែលសកម្មភាពត្រូវបានស្នើសុំឡើង ឬបដិសេធចោល
3. ការពិពណ៌នាពីនីតិវិធីវាយតម្លៃនីមួយៗ កំណត់ត្រា ឬរបាយការណ៍ដែលភ្នាក់ងារបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់សកម្មភាពដែលបានស្នើសុំឡើង ឬបដិសេធចោល
4. សេចក្តីថ្លែងការណ៍ដែលឪពុកម្តាយរបស់កុមារពិការមានការការពារ ស្ថិតក្រោមការការពារតាមនីតិវិធី
5. ប្រភពផ្សេងៗ សម្រាប់ឪពុកម្តាយសម្រាប់ការធ្វើទំនាក់ទំនងដើម្បីទទួលបាននូវជំនួយលើការយល់ដឹងបន្ថែម ពីបទប្បញ្ញត្តិនានាទៅលើផ្នែកនេះ
6. ការពិពណ៌នា ពីជម្រើសផ្សេងទៀតដែលក្រុមការងារ កម្មវិធី IEP បានយកមកធ្វើការពិចារណា និងហេតុផលនានា ដែលជម្រើសទាំងអស់នោះត្រូវបានបដិសេធ; និង
7. ការពិពណ៌នា ពីកត្តាផ្សេងៗទៀត ពាក់ព័ន្ធទៅនឹងសកម្មភាពដែលបានស្នើសុំ ឬបដិសេធ។ (20 *USC* ផ្នែក 1415 [b] [3] និង [4], 141 5 [c] [1] និង 1414 [b] [1] 34 *CFR* ផ្នែក 300.503)

## ការយល់ព្រមពីឪពុកម្តាយសិស្ស

### តើនៅពេលណាដែលខ្ញុំ តម្រូវឱ្យមានការយល់ព្រមទៅលើការវាយតម្លៃ?

អ្នកមានសិទ្ធិក្នុងការបញ្ជូនកូនរបស់អ្នក ទៅកាន់សេវាកម្មអប់រំពិសេស។ អ្នកត្រូវតែផ្តល់ព័ត៌មាន និងផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ មុនពេលដែលការវាយតម្លៃសម្រាប់ការអប់រំពិសេសដំបូង របស់កូនអ្នក អាចដំណើរការទៅបាន។ មាតាបិតាសិស្សមានពេលយ៉ាងតិច 15 ថ្ងៃគិតចាប់ពីថ្ងៃទទួលបានផែនការវាយតម្លៃដែលបានស្នើសុំក្នុងការធ្វើការសម្រេចចិត្ត។ ការវាយតម្លៃអាចនឹងចាប់ផ្តើមធ្វើឡើងភ្លាមៗ នៅពេលដែលបានទទួលនូវការយល់ព្រម និងត្រូវតែធ្វើឱ្យចប់សព្វគ្រប់ ហើយកម្មវិធី IEP នឹងត្រូវបានបង្កើតឡើងក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីមានការយល់ព្រមរបស់អ្នក។

### តើនៅពេលណាដែលខ្ញុំតម្រូវឱ្យមានការការយល់ព្រម ដើម្បីទទួលបានសេវាកម្ម?

អ្នកត្រូវតែផ្តល់ព័ត៌មាន និងផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ មុនពេលមណ្ឌលសិក្សាធិការរបស់អ្នក អាចផ្តល់នូវការអប់រំពិសេស ដល់កូនរបស់អ្នក និងសេវាកម្មពាក់ព័ន្ធនានាទៀត។

### តើមាននីតិវិធីអ្វីខ្លះ នៅពេលដែលមាតាបិតាសិស្ស មិនផ្តល់ការយល់ព្រមទេ?

ប្រសិនបើអ្នកមិនផ្តល់ការយល់ព្រម សម្រាប់ការធ្វើការវាយតម្លៃលើកដំបូង ឬមិនបានឆ្លើយតបទៅនឹងសំណើដើម្បីផ្តល់ការយល់ព្រមទេ មណ្ឌលសិក្សាធិការអាចបន្តការវាយតម្លៃលើកដំបូងរបស់ខ្លួន ដោយប្រើប្រាស់នូវនីតិវិធីសមស្របណាមួយ។

ប្រសិនបើអ្នកបដិសេធមិនយល់ព្រម ទៅលើការផ្តល់សេវាកម្មទេ មណ្ឌលសិក្សាធិការមិនត្រូវផ្តល់ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាទេ ហើយមិនត្រូវស្វែងរកការផ្តល់សេវាកម្មនេះ តាមរយៈដំណើរការនីតិវិធីកំណត់ណាមួយដែរ។

ប្រសិនបើអ្នកយល់ព្រមជាលាយលក្ខណ៍អក្សរ ឱ្យមានការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាដល់កូនរបស់អ្នក ប៉ុន្តែមិនយល់ព្រមចំពោះសមាសភាគទាំងអស់នៃកម្មវិធី IEP ទេ នោះសមាសភាគនៃកម្មវិធីដែលអ្នកបានយល់ព្រម ត្រូវតែអនុវត្តភ្លាមៗ ដោយគ្មានការពន្យាពេលឡើយ។

ប្រសិនបើមណ្ឌលសិក្សាធិការកំណត់ថា សមាសភាគកម្មវិធីអប់រំពិសេសដែលបានស្នើសុំ ដែលអ្នកមិនយល់ព្រម គឺមានភាពចាំបាច់ក្នុងការផ្តល់ជូន កម្មវិធី FAPE ដល់កូនរបស់អ្នក ដំណើរការសវនាការតាមនីតិវិធីកំណត់មួយត្រូវតែចាប់ផ្តើមធ្វើឡើង។ ប្រសិនបើសវនាការតាមនីតិវិធីកំណត់មួយត្រូវបានធ្វើឡើង នោះការសម្រេចនៃអង្គសវនាការ គឺជាការសម្រេចចុងក្រោយ និងជាចំណងផ្លូវច្បាប់ដែលត្រូវអនុវត្តតាម។

ក្នុងករណីមានការវាយតម្លៃឡើងវិញ មណ្ឌលសិក្សាធិការ ត្រូវតែចងក្រងឯកសារពីវិធានការនានាដែលសមហេតុផល ដើម្បីទទួលបានការយល់ព្រមពីអ្នក។ ប្រសិនបើអ្នកខកខានមិនបានឆ្លើយតបទេ មណ្ឌលសិក្សាធិការ អាចបន្តធ្វើការវាយតម្លៃឡើងវិញ ដោយគ្មានការយល់ព្រមពីអ្នកបាន។ (20 *USC* ផ្នែក 1414 [a] [1] [D] និង 1414 [c]; 34 *CFR* ផ្នែក 300.300; ផ្នែក *EC* 56506 [e], 56321 [c] និង [d] និង 56346)។

## តើខ្ញុំអាចលុបចោលនូវការយល់ព្រមនៅពេលណាមួយវិញបាន?

ប្រសិនបើនៅពេលណាមួយ បន្ទាប់ពីការផ្តល់ការអប់រំពិសេសជាលើកដំបូង និងសេវាកម្មពាក់ព័ន្ធនានា មាតាបិតារបស់សិស្សានុសិស្សលុបចោលនូវការយល់ព្រមជាលាយលក្ខណ៍អក្សរ មិនឱ្យបន្តផ្តល់ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាទៀតទេ ភ្នាក់ងាររដ្ឋ៖

1. មិនអាចបន្តផ្តល់ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាដល់សិស្សនោះទៀតទេ ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដោយអនុលោមតាមច្បាប់ 34 *CFR* ផ្នែក 300.503 មុនពេលបញ្ឈប់ការផ្តល់សេវាកម្មនោះ

2. មិនអាចប្រើនីតិវិធីនៅក្នុងអនុផ្នែក E នៃផ្នែក 300 34 *CFR* (រួមទាំងនីតិវិធីការនាំសម្រុះសម្រួលក្រោមច្បាប់ 34 *CFR* ផ្នែក 300.506 ឬដំណើរការនីតិវិធីតាមការកំណត់ណាមួយក្រោមច្បាប់ 34 *CFR* ផ្នែក 300.507 ដល់ 300.516) ដើម្បីទទួលបាននូវកិច្ចព្រមព្រៀង ឬសេចក្តីសម្រេចនានាដែលសេវាកម្មនោះនៅតែអាចមានលទ្ធភាពផ្តល់ដល់សិស្សបានទេ

3. នឹងមិនត្រូវបានគេចាត់ទុកថា ជាការរំលោភបំពានលើលក្ខខណ្ឌតម្រូវក្នុងការធ្វើឱ្យកម្មវិធី FAPE អាចមានផ្តល់ជូនចំពោះសិស្ស ដោយសារតែការខកខានមិនបានផ្តល់ការអប់រំពិសេសដល់សិស្ស និងសេវាកម្មពាក់ព័ន្ធនានាបន្ថែមទៀតនោះទេ

4. មិនតម្រូវឱ្យកោះប្រជុំក្រុមការងារ កម្មវិធី IEP ឬបង្កើតកម្មវិធី IEP ក្រោមច្បាប់ 34 *CFR* ផ្នែក 300.320 និង 300.324 ដល់សិស្ស ក្នុងការផ្តល់ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាបន្ថែមទៀតទេ

សូមចំណាំថា ដោយអនុលោមតាមច្បាប់ 34 *CFR* ផ្នែក 300.9 (c) (3) ប្រសិនបើឪពុកម្តាយសិស្សលុបចោលការយល់ព្រមជាលាយលក្ខណ៍អក្សរ ទៅលើការទទួលបានសេវាកម្ម អប់រំពិសេសសម្រាប់កូនៗរបស់ពួកគេ បន្ទាប់ពីសិស្សត្រូវបានផ្តល់ការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាជាលើកដំបូងរួចហើយ ភ្នាក់ងាអប់រំរដ្ឋ មិនតម្រូវឱ្យធ្វើវិសោធនកម្មលើកំណត់ត្រាអប់រំរបស់សិស្ស ក្នុងការដកចេញនូវឯកសារយោងណាមួយ ទៅលើការទទួលបានការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានារបស់សិស្ស ដោយសារតែការដកចេញនូវការយល់ព្រមរបស់ឪពុកម្តាយសិស្សនោះទេ។

## ការតែងតាំងមាតាជំនួសរបស់សិស្ស

### តើនឹងមានអ្វីកើតឡើង ប្រសិនបើជាមិនអាចកំណត់អត្តសញ្ញាណ ឬទីកន្លែងរបស់ឪពុកម្ដាយសិស្ស បានទេ?

មណ្ឌលសិក្សាធិការ ត្រូវតែធានាថា រូបវន្តបុគ្គលម្នាក់ត្រូវបានតែងតាំងឱ្យដើរតួជាមាតាជំនួសរបស់សិស្ស ធ្វើជាឪពុកម្ដាយរបស់សិស្សដែលមានពិការភាពនោះ នៅពេលដែលឪពុកម្ដាយសិស្ស មិនអាចកំណត់អត្តសញ្ញាណបាន ហើយមណ្ឌលសិក្សាធិការ មិនអាចរកទីកន្លែងរស់នៅ របស់ឪពុកម្ដាយសិស្សឃើញទេ។

មាតាបិតាជំនួស ក៏អាចត្រូវបានតែងតាំងផងដែរ ប្រសិនបើសិស្សនោះជាយុវជនអនាថា គ្មានផ្ទះសម្បែងរស់នៅ ជាជនស្ថិតក្រោមការថែទាំ ឬការគ្រប់គ្រងរបស់តុលាការ ក្រោមក្រមសុខុមាលភាព និងស្ថាប័នរដ្ឋ ហើយត្រូវបានបញ្ជូនទៅទទួលនូវការអប់រំពិសេស ឬទទួលបានកម្មវិធី IEP រួចហើយ។ (20 *USC* ផ្នែក 1415 [b] [2] 34 *CFR* ផ្នែក 300.519 ផ្នែក *EC* 56050 នៃ *ច្បាប់រដ្ឋាភិបាល* ផ្នែក 7579.5 និង 7579.6)

## ការវាយតម្លៃទៅលើការមិនរើសអើង

### តើកូនរបស់ខ្ញុំត្រូវបានវាយតម្លៃដើម្បីទទួលបាន សេវាកម្មអប់រំពិសេស ដោយរបៀបណាដែរ?

អ្នកមានសិទ្ធិឱ្យកូនរបស់អ្នក ទទួលបាននូវការធ្វើការវាយតម្លៃទៅលើផ្នែកដែលទាក់ងនឹងពិការភាពដែលមានការសង្ស័យទាំងអស់។ សម្ភារៈ និងនីតិវិធីដែលប្រើប្រាស់សម្រាប់ការវាយតម្លៃ និងការដាក់សិស្សឱ្យសិក្សា មិនត្រូវមានការប្រកាន់ពូជសាសន៍ វប្បធម៌ ឬការរើសអើងផ្លូវភេទណាមួយឡើយ។

សម្ភារៈសម្រាប់ការធ្វើការវាយតម្លៃត្រូវតែផ្ដល់ជូនឱ្យ ហើយការធ្វើតេស្តត្រូវតែគ្រប់គ្រងធ្វើឡើងជាភាសាកំណើត ឬក្នុងរបៀបនៃការទំនាក់ទំនងរបស់កូនអ្នក ហើយស្ថិតក្នុងទម្រង់នៃការផ្ដល់ព័ត៍មានដែលសុក្រឹតត្រឹមត្រូវ ទៅលើអ្វីដែលសិស្សចេះដឹង និងអាចបំពេញការសិក្សា មានការអភិវឌ្ឍន៍ និងអាចអនុវត្តតាមមុខងារសិក្សាបាន លុះត្រាតែស្ថិតក្នុងលក្ខខណ្ឌមួយ ដែលមិនអាចមានលទ្ធភាពផ្ដល់ឱ្យ ឬគ្រប់គ្រងបានទេ។

គ្មាននីតិវិធីតែមួយ ដែលអាចយកមកប្រើជាលក្ខណៈវិនិច្ឆ័យតែមួយគត់ ក្នុងការកំណត់លើសិទ្ធិទទួលបាន និងការអភិវឌ្ឍន៍ កម្មវិធី FAPE ដល់កូនរបស់អ្នកទេ។ (20 *USC* ផ្នែក 1414 [b] [1] – [3], 1412 [a] [6] [B] 34 *CFR* ផ្នែក 300.304 *EC* ផ្នែក 56001 [j] និង 56320)

## ការវាយតម្លៃឯករាជ្យ សម្រាប់ការអប់រំ

### តើកូនខ្ញុំអាចត្រូវបានធ្វើតេស្តដោយឯករាជ្យ ក្រោមការចំណាយរបស់មណ្ឌលសិក្សាធិការ បានដែរឬទេ?

ប្រសិនបើអ្នកមិនយល់ស្រប ជាមួយនឹងលទ្ធផលនៃការវាយតម្លៃដែលធ្វើឡើងដោយមណ្ឌលសិក្សាធិការទេ អ្នកមានសិទ្ធិស្នើសុំ និងទទួលបាននូវការវាយតម្លៃឯករាជ្យ សម្រាប់ការអប់រំ ដល់កូនរបស់អ្នកពីរូបវន្តបុគ្គលដែលមានសមត្ថភាព ដើម្បីធ្វើការវាយតម្លៃ ដោយរដ្ឋជាអ្នកទទួលខុសត្រូវលើការចំណាយ។

មាតាបិតាសិស្ស មានសិទ្ធិទទួលបាននូវការវាយតម្លៃឯករាជ្យ សម្រាប់ការអប់រំ តែម្តងគត់ដោយរដ្ឋជាអ្នកទទួលខុសត្រូវលើការចំណាយ នៅពេលដែលភ្នាក់ងាររដ្ឋធ្វើការវាយតម្លៃ ហើយមាតាបិតាសិស្សមិនយល់ស្របជាមួយ។

មណ្ឌលសិក្សាធិការត្រូវតែឆ្លើយតបទៅនឹងសំណើរបស់អ្នក ចំពោះការវាយតម្លៃឯករាជ្យ សម្រាប់ការអប់រំ និងត្រូវផ្តល់ឱ្យអ្នកនូវព័ត៌មាននានា ពីទីកន្លែងដែលអាចទទួលបាននូវការវាយតម្លៃដោយឯករាជ្យនេះ។

ប្រសិនបើមណ្ឌលសិក្សាធិការជឿថា ការវាយតម្លៃរបស់ខ្លួនគឺសមស្រប និងមិនឯកភាពថា ការវាយតម្លៃឯករាជ្យគឺមានការចាំបាច់នោះទេ មណ្ឌលសិក្សាធិការត្រូវតែស្នើសុំសវនាការ ទៅតាមដំណើរការនីតិវិធីកំណត់ ដើម្បីបញ្ជាក់ថាការវាយតម្លៃរបស់ខ្លួនគឺសមស្របហើយ។ ប្រសិនបើមណ្ឌលសិក្សាធិការទទួលបានជ័យជម្នះពីអង្គសវនាការ អ្នកនៅតែមានសិទ្ធិក្នុងការទទួលបាននូវការវាយតម្លៃដោយឯករាជ្យ ប៉ុន្តែអ្នកត្រូវទទួលខុសត្រូវលើការចំណាយខ្លួនឯង។ ក្រុមការងារ កម្មវិធី IEP ត្រូវតែធ្វើការពិចារណាទៅលើការវាយតម្លៃដោយឯករាជ្យ។

នីតិវិធីវាយតម្លៃរបស់មណ្ឌល នឹងអនុញ្ញាតឱ្យមានការសង្កេតមេរៀនក្នុងថ្នាក់រៀនរបស់សិស្ស។ ទោះបីជា មណ្ឌលសិក្សាធិការ សង្កេតមើល កូនរបស់អ្នកនៅក្នុងថ្នាក់រៀនរបស់គាត់ ឬរបស់នាង នៅពេលដែលកំពុងធ្វើការវាយតម្លៃ ឬទោះបីជា មណ្ឌលសិក្សាធិការ ត្រូវបានអនុញ្ញាតឱ្យសង្កេតមើលកូនរបស់អ្នកក៏ដោយ

ក៏រូបវន្តបុគ្គលដែលធ្វើការវាយតម្លៃដោយឯករាជ្យ សម្រាប់ការអប់រំ ត្រូវបានអនុញ្ញាតឱ្យសង្កេតមើលកូនរបស់អ្នកនៅក្នុងថ្នាក់ដែរ។

ប្រសិនបើមណ្ឌលសិក្សាធិការស្នើសុំឱ្យមានការកំណត់ជ្រើសរើសសាលារៀនថ្មីដល់កូនរបស់អ្នក ហើយការវាយតម្លៃឯករាជ្យ សម្រាប់ការអប់រំ កំពុងត្រូវបានអនុវត្ត អ្នកវាយតម្លៃឯករាជ្យ ត្រូវបានអនុញ្ញាតឱ្យសង្កេតមើលទៅលើការកំណត់ជ្រើសរើសសាលារៀនថ្មីដែលបានស្នើសុំនោះ ជាមុនសិន។ (20 *USC* ផ្នែក 1415 [b] [1] និង [d] [2] [A] 34 *CFR* ផ្នែក 300.502 *EC* ផ្នែក 56329 [b])

### ការចូលទៅប្រើប្រាស់ កំណត់ត្រាអប់រំ

### តើខ្ញុំអាចពិនិត្យមើលកំណត់ត្រាអប់រំ របស់កូនខ្ញុំបានដែរឬទេ?

អ្នកមានសិទ្ធិត្រួតពិនិត្យ និងពិនិត្យមើលរាល់កំណត់ត្រាសិក្សារបស់កូនអ្នក ដោយមិនមានការពន្យារពេលដែលមិនចាំបាច់ រួមទាំង មុនពេលកិច្ចប្រជុំពីកម្មវិធី IEP របស់កូនអ្នក ឬមុនពេលដំណើរការសវនាការតាមនីតិវិធីកំណត់។ ប្រសិនបើមានការស្នើសុំ មណ្ឌលសិក្សាធិការ ត្រូវតែឱ្យអ្នកចូលប្រើប្រាស់កំណត់ត្រា និងច្បាប់ចម្លងផ្សេងៗ ក្នុងរយៈពេលប្រាំថ្ងៃ **នៃថ្ងៃធ្វើការ**បន្ទាប់ពីការស្នើសុំត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ (*EC* ផ្នែក 49060, 56043 [n] 56501 [b] [3] និង 56504)

## របៀបដោះស្រាយវិវាទ

### ដំណើរការសវនាការតាមនីតិវិធីកំណត់

### តើសវនាការតាមនីតិវិធីកំណត់ ធ្វើនៅពេលណា?

អ្នកមានសិទ្ធិស្នើសុំដំណើរការសវនាការតាមនីតិវិធីកំណត់មិនលំអៀងមួយទាក់ទងនឹងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការដាក់ចុះនូវការអប់រំសម្រាប់កូនរបស់អ្នក ឬការផ្តល់ជូនកម្មវិធី FAPE។ សំណើសម្រាប់ដំណើរការសវនាការតាមនីតិវិធីកំណត់ត្រូវធ្វើឡើងក្នុងរយៈពេល 2 ឆ្នាំ គិតចាប់ពីថ្ងៃដែលអ្នកបានដឹង ឬគួរតែបានដឹង ពីសកម្មភាពដែលត្រូវបានចោទប្រកាន់ដោយបង្កើតបានជាមូលដ្ឋាននៃដំណើរការពាក្យបណ្តឹងតាមនីតិវិធីកំណត់។ (20 *USC* ផ្នែក 1415 [b] [6] 34 *CFR* ផ្នែក 300.507 *EC* ផ្នែក 56501 និង 56505 [l])

## ការនាំសម្រុះសម្រួល និងជម្រើស ដំណោះស្រាយវិវាទផ្សេង

### តើខ្ញុំអាចស្នើសុំឱ្យមានការនាំសម្រុះសម្រួល ឬមធ្យោបាយផ្សេង ដើម្បីដោះស្រាយវិវាទ បានទេ?

សំណើសុំឱ្យមានការនាំសម្រុះសម្រួល អាចត្រូវបានធ្វើឡើងមុន ឬក្រោយពីការស្នើសុំសវនាការតាមនីតិវិធីកំណត់មួយត្រូវបានធ្វើឡើង។

អ្នកអាចស្នើសុំឱ្យមណ្ឌលសិក្សាធិការឱ្យដោះស្រាយវិវាទតាមរយៈការនាំសម្រុះសម្រួល ឬជម្រើសដំណោះស្រាយវិវាទ "alternative dispute resolution" (ADR) ដែលមានលក្ខណៈផ្ទុយគ្នាតិចតួចជាងសវនាការតាមនីតិវិធីកំណត់។ ADR និងការនាំសម្រុះសម្រួល គឺជាវិធីសាស្ត្រស្ម័គ្រចិត្តក្នុងការដោះស្រាយវិវាទ ហើយប្រហែលជាមិនត្រូវបានគេប្រើប្រាស់ដើម្បីពន្យារសិទ្ធិរបស់អ្នកក្នុងដំណើរការសវនាការតាមនីតិវិធីកំណត់ទេ។

### តើអ្វីទៅជាសន្និសីទស្តីពីការនាំសម្រុះសម្រួលមុនសវនាការ?

អ្នកអាចស្វែងរកដំណោះស្រាយតាមរយៈការនាំសម្រុះសម្រួល មុនពេលដាក់សំណើសុំសវនាការតាមនីតិវិធីកំណត់។ សន្និសីទគឺជាដំណើរការក្រៅផ្លូវការមួយ ដែលធ្វើឡើងក្នុងលក្ខណៈមិនប្រកាន់បក្សពួក ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ឬការដាក់ចុះនូវការអប់រំសម្រាប់សិស្ស ឬសម្រាប់កម្មវិធី FAPE។

នៅក្នុងសន្និសីទសម្រុះសម្រួល មុនអង្គសវនាការ មាតាបិតាសិស្ស ឬមណ្ឌលសិក្សាធិការ អាចត្រូវបានអមដំណើរ និងណែនាំ ដោយអ្នកតំណាងដែលមិនមែនជាមេធាវី តែអាចមានការពិគ្រោះយោបល់ជាមួយមេធាវី មុន ឬក្រោយពីសន្និសីទ។ ទោះជាយ៉ាងណាក៏ដោយ ការស្នើសុំ ឬការចូលរួមក្នុងសន្និសីទការនាំសម្រុះសម្រួល មុនអង្គសវនាការ មិនមែនជាតម្រូវការត្រូវធ្វើមុន ការស្នើសុំសវនាការតាមនីតិវិធីកំណត់នោះទេ។

គ្រប់សំណើក្នុងការរៀបចំសន្និសីទការនាំសម្រុះសម្រួល មុនអង្គសវនាការ ត្រូវដាក់ទៅអគ្គនាយកនៃការិយាល័យសវនាការរដ្ឋបាល "Office of Administrative Hearings" (OAH)។ ភាគីដែលផ្តួចផ្តើមធ្វើសន្និសីទ ការនាំសម្រុះសម្រួល មុនអង្គសវនាការ តាមរយៈការដាក់សំណើសុំជាលាយលក្ខណ៍អក្សរទៅអគ្គនាយក OAH ត្រូវផ្តល់ឱ្យភាគីជម្លោះម្ខាងទៀតដែលចូលរួមក្នុងការនាំសម្រុះសម្រួលនេះ នូវច្បាប់ចម្លងនៃសំណើសុំនេះ ក្នុងពេលតែមួយដែលសំណើនេះត្រូវបានដាក់ពាក្យ។

សន្និសីទការនាំសម្រុះសម្រួល មុនអង្គសវនាការ ត្រូវកំណត់ពេលក្នុងរយៈពេល 15 ថ្ងៃ បន្ទាប់ពីការទទួលយកសំណើដោយអគ្គនាយក OAH នៃសំណើសុំការនាំសម្រុះសម្រួល ហើយត្រូវបញ្ចប់ក្នុងរយៈពេល 30 ថ្ងៃ ក្រោយពីបានទទួលសំណើសុំការនាំសម្រុះសម្រួលនេះ លុះត្រាតែភាគីជម្លោះទាំងពីរយល់ព្រមពន្យាពេល។ ប្រសិនបើវិវាទត្រូវបានដោះស្រាយ គ្រប់ភាគីជម្លោះទាំងអស់ ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលមានចំណងផ្លូវច្បាប់ ក្នុងការកំណត់ពីដំណោះស្រាយនេះ។ គ្រប់ការពិភាក្សាទាំងអស់ ក្នុងអំឡុងពេលដំណើរការ ការនាំសម្រុះសម្រួលត្រូវតែរក្សាការសម្ងាត់។ គ្រប់សន្និសីទការនាំសម្រុះសម្រួល មុនអង្គសវនាការទាំងអស់ ត្រូវកំណត់ពេលធ្វើឱ្យបានទាន់ពេលវេលា និងប្រព្រឹត្តទៅតាមពេលវេលាកំណត់ និងធ្វើនៅទីកន្លែងដែលមានផាសុកភាព ប្រកបដោយហេតុផលសមរម្យ សម្រាប់គ្រប់ភាគីទាំងអស់។ ប្រសិនបើបញ្ហានានា មិនអាចដោះស្រាយបានតាមការពេញចិត្តរបស់ភាគីទាំងអស់ទេ ភាគីដែលបានស្នើសុំរៀបចំធ្វើសន្និសីទការនាំសម្រុះសម្រួល មានជម្រើសក្នុងការដាក់ឯកសារសម្រាប់សវនាការតាមនីតិវិធីកំណត់។ (*EC* ផ្នែក 56500.3 និង 56503)

## សិទ្ធិដំណើរការនីតិវិធីតាមការកំណត់

### តើអ្វីជា សិទ្ធិដំណើរការនីតិវិធីតាមការកំណត់ របស់ខ្ញុំ?

អ្នកមានសិទ្ធិ៖

1. ទទួលបាននូវសវនាការរដ្ឋបាលដោយយុត្តិធម៌ និងមិនលំអៀងនៅកម្រិតរដ្ឋនៅចំពោះមុខរូបវន្តបុគ្គលដែលមានចំណេះដឹងផ្នែកច្បាប់ ដែលគ្រប់គ្រងទៅលើការអប់រំពិសេស និងអង្គសវនាការរដ្ឋបាល (20 *USC* ផ្នែក 1415 [f] [1] [A] និង 1415 [f] [3] [A] - [D] 34 *CFR* ផ្នែក 300.511 *EC* ផ្នែក 56501 [b] [4])
2. ការអមដំណើរ និងការណែនាំដោយមេធាវី និង/ឬរូបវន្តបុគ្គលដែលមានចំណេះដឹងពីកុមារពិការ (*EC* ផ្នែក 56505 [e] [1])
3. ទទួលបាន ភស្តុតាងបច្ចុប្បន្ន អំណះអំណាងជាលាយលក្ខណ៍អក្សរ និងអំណះអំណាងផ្ទាល់មាត់ (*EC* ផ្នែក 56505 [e] [2])
4. ការប្រឈមមុខ ការសួរសំណួរផ្សេងៗ និងតម្រូវឱ្យមានវត្តមានសាក្សី (*EC* ផ្នែក 56505 [e] [3])

5. ទទួលបាននូវកំណត់ត្រាពាក្យសំដីអេឡិចត្រូនិកនៃអង្គសវនាការជាលាយលក្ខណ៍អក្សរ ឬទៅតាមជម្រើសរបស់មាតាបិតាសិស្ស រួមទាំងការរកឃើញនូវអង្គហេតុ និងការសម្រេចចិត្តនានា (*EC* ផ្នែក 56505 [e] [4])
6. ឱ្យកូនរបស់អ្នកមានវត្តមាននៅក្នុងអង្គសវនាការ (*EC* ផ្នែក 56501 [c] [1])
7. ឱ្យអង្គសវនាការបើកជាសាធារណៈ ឬជាឯកជន (*EC* ផ្នែក 56501 [c] [2])
8. ទទួលបានឯកសារច្បាប់ចម្លងទាំងអស់ រួមទាំងការវាយតម្លៃដែលបានបញ្ចប់នៅថ្ងៃនោះផងដែរ អនុសាសន៍ផ្សេងៗ ព្រមទាំងបញ្ជីសាក្សី និងផ្នែកទូទៅនៃសក្ខីកម្មរបស់ពួកគេក្នុងរយៈពេលប្រាំ (5) ថ្ងៃ នៃថ្ងៃធ្វើការមុនពេលអង្គសវនាការ (*EC* ផ្នែក 56505 [e] [7] និង 56043 [v])
9. ត្រូវបានជូនដំណឹងដោយភាគីផ្សេងទៀតពីបញ្ហានានា និងដំណោះស្រាយដែលបានស្នើសុំរបស់ពួកគេ ទៅលើបញ្ហាទាំងអស់នោះ យ៉ាងហោចណាស់ដប់ (10) ថ្ងៃ នៃប្រតិទិន មុនពេលអង្គសវនាការ (*EC* ផ្នែក 56505 [e] [6])
10. ផ្ដល់ជូនអ្នកបកប្រែភាសាផ្ទាល់មាត់ (*ច្បាប់នៃបទប្បញ្ញត្តិ រដ្ឋកាលីហ្វ័រញ៉ា "California Code of Regulations"* ជំពូកទី 5 (5 *CCR*) ផ្នែក 3082 [d])
11. ស្នើសុំពន្យាពេលអង្គសវនាការ (*EC* ផ្នែក 56505 [f] [3])
12. ទទួលបានសន្និសីទការនាំសម្រុះសម្រួលនៅចំណុចណាមួយក្នុងអំឡុងពេលនៃដំណើរការអង្គសវនាតាមនីតិវិធីកំណត់ (*EC* ផ្នែក 56501 [b] [2]) និង
13. ទទួលបានការជូនដំណឹងពីភាគីជម្លោះម្ខាងទៀតយ៉ាងតិចបំផុតដប់ថ្ងៃមុនអង្គសវនាការ ប្រសិនភាគីជម្លោះនោះ មានបំណងយកតំណាងមេធាវី (*EC* ផ្នែក 56507 [a]) (20 *USC* ផ្នែក 1415 [e] 34 *CFR* ផ្នែក 300.506, 300.508, 300.512 និង 300.515)

## ការដាក់ពាក្យបណ្ដឹងដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ

### តើខ្ញុំស្នើសុំអង្គសវនាការតាមនីតិវិធីដោយរបៀបណាដែរ?

អ្នកត្រូវដាក់សំណើសុំជាលាយលក្ខណ៍អក្សរសម្រាប់អង្គសវនាការតាមនីតិវិធី។ អ្នក ឬអ្នកតំណាងរបស់អ្នក ត្រូវដាក់បញ្ជូនព័ត៌មានខាងក្រោមនេះ នៅក្នុងសំណើរបស់អ្នកៈ

1. ឈ្មោះរបស់សិស្ស
2. អាសយដ្ឋានលំនៅឋានរបស់សិស្ស

3. ឈ្មោះសាលាដែលកូនអ្នករៀន
4. ក្នុងករណីដែលសិស្ស ជាសិស្សអនាថា ត្រូវផ្តល់ព័ត៌មានទំនាក់ទំនងណាដែលមានសម្រាប់សិស្ស និងឈ្មោះសាលាដែលសិស្សកំពុងរៀន និង
5. ការពិពណ៌នា ពីលក្ខណៈនៃបញ្ហា រួមទាំងអង្គហេតុដែលទាក់ទងនឹងបញ្ហា (នានា) និងសំណើដំណោះស្រាយទៅលើបញ្ហា (នានា) ទាំងអស់នោះ

ច្បាប់សហព័ន្ធ និងច្បាប់រដ្ឋតម្រូវឱ្យភាគីណាមួយដែលបានដាក់ឯកសារស្នើសុំអង្គសវនាការតាមនីតិវិធី ត្រូវផ្តល់ច្បាប់ចម្លងនៃសំណើជាលាយលក្ខណ៍អក្សរទៅភាគីជម្លោះម្ខាងទៀត។ (20 *USC* ផ្នែក 1415 [b] [7] និង 1415 [c] [2] 34*CFR* ផ្នែក 300.508 *EC* ផ្នែក 56502 [c] [1])

មុនពេលដាក់ពាក្យស្នើសុំអង្គសវនាការតាមនីតិវិធីកំណត់ មណ្ឌលសិក្សាធិការត្រូវផ្តល់ឱកាសក្នុងការដោះស្រាយបញ្ហា តាមរយៈការប្រជុំដោះស្រាយបញ្ហា ដែលជាការប្រជុំ រវាងឪពុកម្តាយសិស្ស និងសមាជិកពាក់ព័ន្ធនៃក្រុមការងារ កម្មវិធី IEP ដែលមានចំណេះដឹងជាក់លាក់ច្បាស់លាស់ ពីអង្គហេតុដែលបានកំណត់អត្តសញ្ញាណឡើង នៅក្នុងសំណើអង្គសវនាការតាមនីតិវិធីកំណត់។ (20 *USC* ផ្នែក 1415 [f] [1] [B] 34 *CFR* ផ្នែក 300.510)

**តើ ដំណើរការប្រជុំដោះស្រាយបញ្ហា មានអ្វីខ្លះ?**

ដំណើរការប្រជុំដោះស្រាយបញ្ហា ត្រូវកោះប្រជុំក្នុងរយៈពេល 15 ថ្ងៃ ក្រោយពីទទួលបានសេចក្តីជូនដំណឹង ពីសំណើអង្គសវនាការតាមនីតិវិធីកំណត់របស់ឪពុកម្តាយសិស្ស។ ដំណើរការប្រជុំដោះស្រាយបញ្ហា ត្រូវរាប់បញ្ចូលទាំងអ្នកតំណាងពីមណ្ឌលសិក្សាធិការ ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងមិនរាប់បញ្ចូលមេធាវីរបស់មណ្ឌលសិក្សាធិការទេ លុះត្រាតែមាតាបិតាសិស្សមានមេធាវីដែរ។ ឪពុកម្តាយសិស្ស អាចពិភាក្សា ពីបញ្ហាអង្គសវនាការតាមនីតិវិធីកំណត់ និងអង្គហេតុនានា ដែលបង្កើតបានជាមូលដ្ឋាននៃសំណើអង្គសវនាការតាមនីតិវិធីកំណត់។

ដំណើរការប្រជុំដោះស្រាយបញ្ហា មិនមានការតម្រូវឱ្យធ្វើទេ ប្រសិនបើមាតាបិតាសិស្ស និងមណ្ឌលសិក្សាធិការយល់ព្រមគ្នាជាលាយលក្ខណ៍អក្សរលុបចោលការប្រជុំនេះចេញ។ ប្រសិនបើមណ្ឌលសិក្សាធិការមិនបានដោះស្រាយបញ្ហាអង្គសវនាការទៅតាមនីតិវិធីក្នុងរយៈពេល 30 ថ្ងៃទេ អង្គសវនាការតាមនីតិវិធីអាចនឹងប្រព្រឹត្តទៅ។ ប្រសិនបើទទួលបាននូវដំណោះស្រាយ

ភាគីជម្លោះត្រូវអនុវត្តតាមកិច្ចព្រមព្រៀងដែលជាចំណងផ្លូវច្បាប់ទាំងអស់គ្នា។ (20 *USC* ផ្នែក 1415 [f] [1] [B] 34 *CFR* ផ្នែក 300.510)

## តើទីកន្លែងសិក្សារបស់កូនខ្ញុំ នឹងមានការផ្លាស់ប្តូរដែរឬទេ នៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី?

សិស្សដែលចូលរួមក្នុងដំណើរការរដ្ឋបាល ឬតុលាការ ត្រូវតែស្ថិតនៅក្នុងកន្លែងសិក្សាបច្ចុប្បន្ន លុះត្រាតែអ្នក និងមណ្ឌលសិក្សាធិការ យល់ព្រមឱ្យមានការរៀបចំកន្លែងសិក្សាថ្មីមួយផ្សេងទៀតដល់ពួកគេ។ ប្រសិនបើអ្នកកំពុងដាក់ពាក្យស្នើសុំចូលរៀនជាលើកដំបូងសម្រាប់កូនអ្នកទៅសាលារដ្ឋ កូនរបស់អ្នកនឹងត្រូវបានដាក់ឱ្យសិក្សានៅក្នុងកម្មវិធីសិក្សាសាលារដ្ឋ ដោយមានការយល់ព្រមពីអ្នក រហូតដល់ដំណើរការនីតិវិធីគ្រប់យ៉ាងត្រូវបានបញ្ចប់ចប់សព្វគ្រប់។ (20 *USC*ផ្នែក 1415 [j] 34 *CFR* ផ្នែក 300.518; *EC* ផ្នែក 56505 [d])

## តើការសម្រេចចិត្ត អាចប្តឹងសាទុក្ខបានទេ?

សេចក្តីសម្រេចនៃអង្គសវនាការគឺជាការសម្រេចចុងក្រោយ និងមានចំណងផ្លូវច្បាប់ចំពោះភាគីជម្លោះទាំងសងខាង។ ភាគីជម្លោះទាំងសងខាងអាចប្តឹងសាទុក្ខបាន ទៅលើសេចក្តីសម្រេចនៃអង្គសវនាការដោយដាក់បណ្តឹងរដ្ឋប្បវេណីទៅតុលាការរដ្ឋ ឬតុលាការសហព័ន្ធ ក្នុងរយៈពេល 90 ថ្ងៃនៃសេចក្តីសម្រេចចុងក្រោយ។ (20 *USC* ផ្នែក 1415 [i] [2] និង [3] [A] និង 1415 [l] 34 *CFR* ផ្នែក 300.516 *EC* ផ្នែក 56505 [h] និង [k] *EC* ផ្នែក 56043 [w])

## តើអ្នកណាជាអ្នកបង់ថ្លៃមេធាវីរបស់ខ្ញុំ?

នៅក្នុងសកម្មភាព ឬដំណើរការនីតិវិធីណាមួយ ដែលទាក់ទងនឹងអង្គសវនាការតាមនីតិវិធីកំណត់ តាមការសម្រេចចិត្តរបស់ខ្លួន តុលាការ អាចផ្តល់តម្លៃមេធាវីដែលមានតម្លៃសមរម្យ ដែលជាផ្នែកមួយនៃការចំណាយសម្រាប់អ្នក ក្នុងនាមជាឪពុកម្តាយសិស្ស ដែលមានពិការភាព ប្រសិនបើអ្នកជាភាគីដែលឈ្នះក្តីនៅក្នុងអង្គសវនាការ។ តម្លៃមេធាវីសមរម្យក៏អាចត្រូវបានផ្តល់ជូនឱ្យ ក្រោយពីការបញ្ចប់នៃអង្គសវនាការរដ្ឋបាល ដោយមានការយល់ព្រមពីភាគីជម្លោះទាំងអស់ផងដែរ។ (20 *USC* ផ្នែក 1415 [i] [3] [B] – [G] 34 *CFR* ផ្នែក 300.517 *EC* ផ្នែក 56507 [b])

តម្លៃសេវា អាចត្រូវបានកាត់បន្ថយខ្លះ ប្រសិនបើមានលក្ខខណ្ឌណាមួយខាងក្រោម៖

1. តុលាការកឃើញថា អ្នកបានពន្យារពេលដោយមិនសមហេតុផលក្នុងការដោះស្រាយវិវាទចុងក្រោយ
2. ថ្លៃឈ្នួលប្រចាំម៉ោងរបស់មេធាវី លើសពីអត្រាតម្លៃដែលមានស្រាប់នៅក្នុងសហគមន៍ សម្រាប់សេវាកម្មស្រដៀងគ្នានេះដែ ចំពោះមេធាវីដែលមានជំនាញ កេរ្តិ៍ឈ្មោះ និងបទពិសោធន៍ ដែលអាចយកមកប្រៀបធៀបគ្នាបាន
3. ពេលវេលាដែលបានចំណាយជាក់ស្តែង និងសេវាកម្មផ្លូវច្បាប់ដែលបានផ្តល់ឱ្យគឺមានភាពហួសប្រមាណ ឬ
4. មេធាវីរបស់អ្នកមិនបានផ្តល់ព័ត៌មានសមស្រប ទៅដល់មណ្ឌលសិក្សាធិការនៅក្នុងសេចក្តីជូនដំណឹង ពីដំណើរការនីតិវិធីតាមការកំណត់នោះទេ។

ទោះជាយ៉ាងណាក៏ដោយ ថ្លៃមេធាវីនឹងមិនត្រូវបានកាត់បន្ថយទេ ប្រសិនបើតុលាការរកឃើញថា រដ្ឋ ឬមណ្ឌលសិក្សាធិការបានពន្យារពេលវេលា ដោយមិនសមហេតុផល ទៅលើដំណោះស្រាយចុងក្រោយនៃសកម្មភាព ឬដំណើរការនីតិវិធី ឬមានការរំលោភបំពានទៅលើផ្នែកនៃច្បាប់នេះ។ (20 *USC* ផ្នែក 1415 [i] [3] [B] - [G] 34 *CFR* ផ្នែក 300.517)

ថ្លៃមេធាវីទាក់ទងនឹងកិច្ចប្រជុំណាមួយនៃក្រុមការងារ កម្មវិធី IEP អាចនឹងមិនត្រូវបានផ្តល់ជូនឱ្យទេ លុះត្រាតែការប្រជុំក្រុមការងារ កម្មវិធី IEP ត្រូវបានកោះប្រជុំឡើង ដែលជាលទ្ធផលនៃដំណើរការសវនាការតាមនីតិវិធី ឬជាចំណាត់ការរបស់តុលាការ។ តម្លៃមេធាវីក៏អាចត្រូវបានបដិសេធដែរ ប្រសិនបើអ្នកបដិសេធចំពោះការផ្តល់ជូនដំណោះស្រាយសមហេតុផល ដែលធ្វើឡើងដោយមណ្ឌល/ភ្នាក់ងាររដ្ឋ នៅ 10 ថ្ងៃមុនពេលអង្គសវនាការចាប់ផ្តើម ហើយការសម្រេចនៃអង្គសវនាការ គឺមិនល្អប្រសើរ ជាងការផ្តល់ជូនដំណោះស្រាយ ដោយមណ្ឌល/ភ្នាក់ងាររដ្ឋនោះទេ។ (20 *USC* ផ្នែក 1415 [i] [3] [B] – [G] 34 *CFR* ផ្នែក 300.517)

**ដើម្បីទទួលបានព័ត៌មានបន្ថែម ឬដាក់ឯកសារ សម្រាប់ការនាំសម្រុះសម្រួល ពី OAH ឬដំណើរការអង្គសវនាការតាមនីតិវិធី សូមទាក់ទងទៅ៖**

[Office of Administrative Hearings
Attention: Special Education Division
2349 Gateway Oaks Drive, Suite 200
Sacramento, CA 95833-4231
Phone: 916-263-0880

Fax: 916-376-4207]

អ្នកក៏អាចទាក់ទង OAH បាន តាមអ៊ីមែលដោយប្រើប្រព័ន្ធដាក់បញ្ជូនឯកសារអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព "Secure e-File Transmission" (SFT) បានដែរ។ អ្នកអាចរក SFT នៅលើគេហទំព័ររបស់ OAH បាននៅ https://www.applications.dgs.ca.gov/OAH/oahSFTWeb

## វិន័យសាលារៀន និងនិតិវិធីនៃការដាក់សិស្សពិការចូលរៀន

## វិន័យសាលារៀន និងការកំណត់ការអប់រំជំនួសបណ្តោះអាសន្ន

### តើកូនរបស់ខ្ញុំអាចត្រូវបានព្យួរពីការសិក្សា ឬបណ្តេញចេញដែរឬទេ?

បុគ្គលិកសាលារៀន អាចធ្វើការពិចារណាទៅលើកាលៈទេសៈពិសេសណាមួយទៅតាមសំណុំរឿងនីមួយៗ នៅពេលកំណត់ថាតើ ការផ្លាស់ប្តូរកន្លែងសិក្សាថ្មី មានលក្ខណៈសមស្រប សម្រាប់សិស្សពិការដែលបានរំលោភបំពានទៅលើក្រមសីលធម៌សិស្ស ចំពោះការកំណត់ការផ្លាស់ប្តូរកន្លែងសិក្សាថ្មីដល់គាត់ ឬនាងដែរឬទេ៖

- ការកំណត់ការអប់រំជំនួសបណ្តោះអាសន្នដែលសមស្រប ការកំណត់ថ្មីមួយផ្សេងទៀត ឬការព្យួរការសិក្សាសម្រាប់រយៈពេលមិនលើសពី 10 ថ្ងៃ នៃថ្ងៃសិក្សាជាប់ៗគ្នា
- ការដកចេញពីការសិក្សាបន្ថែមមិនលើសពី 10 ថ្ងៃ នៃថ្ងៃសិក្សាជាប់ៗគ្នាក្នុងឆ្នាំសិក្សាដូចគ្នា សម្រាប់ឧប្បត្តិហេតុនៃការប្រព្រឹត្តខុសវិន័យសាលារៀនដាច់ដោយឡែកពីគ្នា

### តើមានអ្វីកើតឡើងបន្ទាប់ពីការដកសិស្សចេញពីការសិក្សា លើសពី 10 ថ្ងៃទៅ?

បន្ទាប់ពីសិស្សពិការត្រូវបានដកចេញពីកន្លែងសិក្សាបច្ចុប្បន្ន របស់គាត់ ឬរបស់នាង រយៈពេល 10 ថ្ងៃ នៃថ្ងៃសិក្សាក្នុងឆ្នាំសិក្សាដដែលនោះ នៅថ្ងៃបន្ទាប់នៃការដកសិស្សពិការចេញពីការសិក្សា ភ្នាក់ងាររដ្ឋ ត្រូវតែផ្តល់ជូនសេវាកម្មដល់សិស្សនោះ ដើម្បីឱ្យសិស្សអាចបន្តចូលរួមក្នុងកម្មវិធីសិក្សាទូទៅបាន និងមានវឌ្ឍភាពឆ្ពោះទៅសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុង កម្មវិធី IEP របស់សិស្ស។ បន្ថែមលើសនេះទៀត សិស្សនឹងទទួលបាននូវការវាយតម្លៃ លើអាកប្បកិរិយា និងសេវាអន្តរាគមន៍អាកប្បកិរិយា និងការកែប្រែនានា

ដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយការរំលោភបំពានទៅលើអាកប្បកិរិយា ដើម្បីកុំឱ្យបញ្ហានេះកើតឡើងម្តងទៀត។

ប្រសិនបើមានការដាក់សិស្សលើសពី 10 ថ្ងៃនៅក្នុងកន្លែងបែបនេះ ការប្រជុំក្រុមការងារ កម្មវិធី IEP ត្រូវតែធ្វើឡើង ដើម្បីកំណត់ថាតើការប្រព្រឹត្តខុសរបស់សិស្ស គឺបណ្តាលមកពីពិការភាពដែរឬទេ។ កិច្ចប្រជុំក្រុមការងារ កម្មវិធី IEP នេះ ត្រូវតែធ្វើឡើងភ្លាមៗ ប្រសិនបើអាចធ្វើទៅបាន ឬធ្វើឡើងក្នុងរយៈពេល 10 ថ្ងៃ នៃការសម្រេចចិត្តរបស់មណ្ឌលសិក្សាធិការ ដើម្បីដាក់ចេញនូវវិធានការវិន័យប្រភេទនេះ។

ក្នុងនាមជាមាតាបិតាសិស្ស អ្នកនឹងត្រូវបានអញ្ជើញឱ្យចូលរួមជាសមាជិកនៃក្រុមការងារ កម្មវិធី IEP នេះផងដែរ។ មណ្ឌលសិក្សាធិការអាចត្រូវបានតម្រូវឱ្យបង្កើតផែនការវាយតម្លៃ ដើម្បីដោះស្រាយការប្រព្រឹត្តខុសវិន័យសាលារបស់សិស្ស ឬប្រសិនបើ កូនរបស់អ្នកមានផែនការអន្តរាគមន៍អាកប្បកិរិយា សូមពិនិត្យមើលផែនការនោះ និងកែប្រែផែនការតាមការចាំបាច់ជាក់ស្តែង។

## តើមានអ្វីកើតឡើងប្រសិនបើក្រុមការងារ កម្មវិធី IEP កំណត់ថាការប្រព្រឹត្តខុសវិន័យសាលារបស់សិស្ស មិនមែនបណ្តាលមកពីពិការភាពនោះទេ?

ប្រសិនបើក្រុមការងារ កម្មវិធី IEP ធ្វើការសន្និដ្ឋានថា ការប្រព្រឹត្តខុសវិន័យសាលារបស់សិស្ស មិនមែនដោយសារពិការភាពរបស់សិស្សទេ មណ្ឌលសិក្សាធិការអាចចាត់វិធានការវិន័យ ដូចជាការបណ្តេញចេញពីសាលា ក្នុងលក្ខណៈដូចគ្នាដែលសាលាអនុវត្តចំពោះសិស្សដែលគ្មានពិការភាពដែរ។ (20 *USC* ផ្នែក 1415 [k] [1] និង [7] 34 *CFR* ផ្នែក 300.530)

ប្រសិនបើអ្នកមិនយល់ស្របចំពោះការសម្រេចរបស់ក្រុមការងារ កម្មវិធី IEP ទេ អ្នកអាចស្នើសុំសវនាតាមនីតិវិធីកំណត់ឱ្យបានឆាប់រហ័ស ដែលត្រូវធ្វើឡើងក្នុងរយៈពេល 20 ថ្ងៃ នៃថ្ងៃសិក្សា ចាប់ពីថ្ងៃដែលអ្នកបានស្នើសុំសវនាការ។ (20 *USC* ផ្នែក 1415 [k] [2] 34 *CFR* ផ្នែក 300.531 [c])

ដោយមិនគិតពីការកំណត់នេះ មណ្ឌលសិក្សាធិការត្រូវតែបន្តផ្តល់ កម្មវិធីសិក្សា FAPE ដល់កូនរបស់អ្នក។ ការកំណត់លើជម្រើស សម្រាប់ការអប់រំនេះ ត្រូវតែអនុញ្ញាតឱ្យសិស្សបន្តចូលរួមនៅក្នុងកម្មវិធីសិក្សាទូទៅ និងធានាបាននូវការបន្តផ្តល់សេវាកម្មនានា និងការកែប្រែលម្អិតនៅក្នុងកម្មវិធីសិក្សា IEP។ (34 *CFR* ផ្នែក 300.530 *EC* ផ្នែក 48915.5 [b])

## សិស្សដែលចូលរៀននៅសាលាឯកជន

### តើសិស្សដែលត្រូវបានឪពុកម្ដាយដាក់ឱ្យសិក្សានៅសាលាឯកជនអាចចូលរួមក្នុងកម្មវិធីអប់រំពិសេសដែលផ្ដល់មូលនិធិដោយរដ្ឋបានដែរឬទេ?

សិស្សដែលត្រូវបានចុះឈ្មោះដោយឪពុកម្ដាយរបស់ពួកគេនៅក្នុងសាលាឯកជន អាចចូលរួមក្នុងកម្មវិធីអប់រំពិសេសដែលផ្ដល់មូលនិធិដោយរដ្ឋបាន។ មណ្ឌលសិក្សាធិការត្រូវតែពិគ្រោះយោបល់ជាមួយសាលាឯកជន និងពិគ្រោះយោបល់ជាមួយមាតាបិតាសិស្ស ដើម្បីកំណត់សេវាកម្មដែលនឹងត្រូវផ្ដល់ជូនដល់សិស្សដែលមកពីសាលាឯកជន។ ទោះបីជាមណ្ឌលសិក្សាធិការមានទំនួលខុសត្រូវច្បាស់លាស់ក្នុងការផ្ដល់ជូន កម្មវិធីសិក្សា FAPE ដល់សិស្សពិការក៏ដោយ សិស្សពិការទាំងនោះ នៅពេលដែលដាក់ឱ្យសិក្សានៅក្នុងសាលាឯកជនដោយឪពុកម្ដាយរបស់ពួកគេ មិនមានសិទ្ធិទទួលបាននូវការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាមួយចំនួន ឬសេវាកម្មទាំងអស់ ដែលចាំបាច់ដើម្បីផ្ដល់ជូនកម្មវិធីសិក្សា FAPE នោះទេ។ (20 *USC* ផ្នែក 1415 [a] [10] [A] 34 *CFR* ផ្នែក 300.137 និង 300.138; *EC* ផ្នែក 56173)

ប្រសិនបើមាតាបិតាសិស្សដែលមានតម្រូវការពិសេស ដែលពីមុនបានទទួលការអប់រំពិសេស និងសេវាកម្មពាក់ព័ន្ធនានាក្រោមសិទ្ធិអំណាចរបស់មណ្ឌលសិក្សាធិការ ចុះឈ្មោះសិស្សនៅក្នុងសាលាបឋមសិក្សា ឬអនុវិទ្យាល័យឯកជន ដោយគ្មានការយល់ព្រម ឬការបញ្ជូន ពីភ្នាក់ងារអប់រំក្នុងមូលដ្ឋានទេ មណ្ឌលសិក្សាធិការ មិនតម្រូវឱ្យផ្ដល់ការអប់រំពិសេសទេ ប្រសិនបើមណ្ឌលមានផ្ដល់ជូនកម្មវិធី FAPE។ តុលាការ ឬមន្ត្រីសវនាការតាមនីតិវិធីអាចតម្រូវឱ្យមណ្ឌលសិក្សាធិការសងសំណងដល់មាតាបិតា ឬអាណាព្យាបាលសិស្ស សម្រាប់ថ្លៃសិក្សាពិសេស និងសាលាឯកជន លុះត្រាណាតែតុលាការ ឬមន្ត្រីសវនាការតាមនីតិវិធី រកឃើញថា មណ្ឌលសិក្សាធិការមិនបានផ្ដល់ជូនកម្មវិធី FAPE សម្រាប់សិស្ស ឱ្យបានទាន់ពេលវេលា មុនពេលពួកគេចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ឬអនុវិទ្យាល័យឯកជន ហើយរកឃើញថាការដាក់ឱ្យសិក្សានៅសាលាឯកជនគឺសមស្រប។ (20 *USC* ផ្នែក 1412 [a] [10] [C] 34 *CFR* ផ្នែក 300.148 *EC* ផ្នែក 56175)

### តើនៅពេលណាដែលការទូទាត់សំណងអាចត្រូវបានកាត់បន្ថយចំនួន ឬបដិសេធ?

តុលាការ ឬមន្ត្រីសវនាការអាចកាត់បន្ថយ ឬបដិសេធការទូទាត់សំណង ប្រសិនបើអ្នកមិនបានធ្វើឱ្យកូនរបស់អ្នកមានលទ្ធភាពក្នុងការវាយតម្លៃតាមការជូនដំណឹងពីមណ្ឌលសិក្សាធិការ មុនពេលដកកូនរបស់អ្នកចេញពីសាលារដ្ឋ។ អ្នកក៏អាចត្រូវបានបដិសេធមិនផ្ដល់សំណងឱ្យដែរ

ប្រសិនបើអ្នកមិនបានជូនដំណឹងដល់មណ្ឌលសិក្សាធិការថា
អ្នកកំពុងបដិសេធពីកន្លែងអប់រំពិសេសដែលបានស្នើសុំដោយមណ្ឌលសិក្សាធិការ
រួមទាំងការបញ្ជាក់ពីកង្វល់របស់អ្នក
និងបំណងក្នុងការចុះឈ្មោះកូនរបស់អ្នកនៅក្នុងសាលាឯកជនដោយរដ្ឋជាអ្នកទទួលខុសត្រូវលើចំណាយ។

អ្នកត្រូវជូនដំណឹងដល់មណ្ឌលសិក្សាធិការតាមវិធីណាមួយដូចខាងក្រោម៖

- នៅកិច្ចប្រជុំក្រុមការងារ កម្មវិធី IEP ថ្មីៗបំផុតដែលអ្នកបានចូលរួមមុនពេលដកកូនរបស់អ្នកចេញពីសាលារដ្ឋ ឬ
- ជាលាយលក្ខណ៍អក្សរទៅកាន់មណ្ឌលសិក្សាធិការយ៉ាងហោចណាស់ 10 ថ្ងៃនៃថ្ងៃធ្វើការ (រួមទាំងថ្ងៃឈប់សម្រាកបុណ្យ) មុនពេលដកកូនរបស់អ្នកចេញពីសាលារដ្ឋ។ (20 *USC* ផ្នែក 1412 [a] [10] [C] 34 *CFR* ផ្នែក 300.148 *EC*ផ្នែក 56176)

## តើនៅពេលណាដែលការទូទាត់សំណងមិនត្រូវបានកាត់បន្ថយ ឬបដិសេធ?

តុលាការ ឬមន្ត្រីសវនាការមិនត្រូវកាត់បន្ថយ ឬបដិសេធការទូទាត់សំណងជូនអ្នកទេ ប្រសិនបើអ្នកខកខានមិនបានផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅមណ្ឌលសិក្សាធិការ ដោយហេតុផលណាមួយខាងក្រោម៖

- សាលាបានរារាំងអ្នកមិនឱ្យផ្តល់ការជូនដំណឹងនេះ
- អ្នកមិនបានទទួលច្បាប់ចម្លងនៃសេចក្តីជូនដំណឹងស្តីពីការការពារតាមនីតិវិធីនេះ ឬមិនត្រូវបានគេជូនដំណឹង ពីលក្ខខណ្ឌតម្រូវក្នុងការជូនដំណឹងដល់មណ្ឌលទេ
- ការជូនដំណឹងនេះ អាចមានផលប៉ះពាល់ដល់រាងកាយកូនរបស់អ្នក
- អនក្ខរភាព
  និងអសមត្ថភាពក្នុងការសរសេរជាភាសាអង់គ្លេសបានរារាំងអ្នកមិនអាចឱ្យធ្វើការជូនដំណឹងបាន ឬ
- ការជូនដំណឹងអាចមានផលប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរដល់កូនរបស់អ្នក

(20 *USC* ផ្នែក 1412 [a] [10] [C] 34 *CFR* ផ្នែក 300.148 *EC*ផ្នែក 56177)

## នីតិវិធីបណ្តឹងរដ្ឋ

### តើខ្ញុំអាចដាក់ពាក្យបណ្តឹងលើការអនុលោមតាមច្បាប់របស់រដ្ឋនៅពេលណាដែរ?

អ្នកអាចដាក់ពាក្យបណ្តឹង លើការអនុលោមតាមច្បាប់របស់រដ្ឋ នៅពេលអ្នកជឿជាក់ថាមណ្ឌលសិក្សាធិការមួយ បានបំពានលើច្បាប់ ឬបទប្បញ្ញត្តិអប់រំពិសេសរបស់សហព័ន្ធ ឬរដ្ឋ។ ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សររបស់អ្នកត្រូវតែបញ្ជាក់ពីមូលហេតុយ៉ាងហោចណាស់មួយ ពីការរំលោភបំពានលើច្បាប់អប់រំពិសេសរបស់សហព័ន្ធ និងរដ្ឋ។ ការរំលោភបំពានត្រូវតែកើតឡើង ដោយមិនឱ្យលើសពីរយៈពេលមួយឆ្នាំមុនកាលបរិច្ឆេទដែលពាក្យបណ្តឹងត្រូវបានទទួលដោយ CDE។ នៅពេលដាក់ពាក្យបណ្តឹង អ្នកត្រូវតែបញ្ជូនច្បាប់ចម្លងនៃពាក្យបណ្តឹងទៅមណ្ឌលសិក្សាធិការ ក្នុងពេលដំណាលគ្នាដែលអ្នកដាក់ពាក្យបណ្តឹងលើការអនុលោមតាមច្បាប់របស់រដ្ឋជាមួយ CDE ដែរ។ (34 *CFR* ផ្នែក 300.151–153 5 *CCR* ផ្នែក 4600)

ពាក្យបណ្តឹងដែលចោទប្រកាន់ពីការរំលោភបំពានលើច្បាប់អប់រំពិសេសរបស់សហព័ន្ធ និងរដ្ឋអាចត្រូវបានផ្ញើទៅ៖

[California Department of Education
Special Education Division
Complaint Support Unit
1430 N Street, Suite 2401
Sacramento, CA 95814]

អ្នកក៏អាចផ្ញើអ៊ីមែលពាក្យបណ្តឹងរបស់អ្នកទៅកាន់ speceducation@cde.ca.govផងដែរ

សម្រាប់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងបញ្ហាដែលមិនស្ថិតក្រោមច្បាប់ ឬបទប្បញ្ញត្តិអប់រំពិសេសរបស់សហព័ន្ធ ឬរដ្ឋ សូមពិគ្រោះយោបល់ជាមួយនីតិវិធីបណ្តឹងស្តង់ដាក្នុងមណ្ឌលរបស់អ្នក។

ដើម្បីទទួលបានព័ត៌មានបន្ថែម ពីការដោះស្រាយវិវាទ រួមទាំងរបៀបដាក់ពាក្យបណ្តឹង សូមទាក់ទងទៅ CDE, ផ្នែកអប់រំពិសេស "Special Education Division" អង្គភាពគាំទ្រពាក្យបណ្តឹង "Complaint Support Unit" តាមរយៈទូរសព្ទលេខ 800-926-0648; តាមទូរសារ 916-327-3704; ឬចូលទៅកាន់គេហទំព័រ CDE, ការអប់រំពិសេស "Special Education" នៅ https://www.cde.ca.gov/sp/se/index.asp។

## ការជួយគាំទ្រដល់គ្រួសារ

### ច្បាប់ព្រឹទ្ធសភាលេខ 511 មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាចគ្រួសារ

### សាវតា

មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាចគ្រួសារ "Family Empowerment Centers" (FECs) ត្រូវបានបង្កើតឡើងនៅក្នុងជំពូកទី 690 នៃលក្ខន្តិកៈឆ្នាំ 2001 (ច្បាប់ព្រឹទ្ធសភាលេខ 511, Alpert) ដែលបានអនុម័តជា *ច្បាប់អប់រំ "Education Code"* (*EC*) 56400-56415។ FECs ផ្តល់សេវាកម្មដល់គ្រួសារដែលមានកុមារពិការដែលមានអាយុពី 3 ឆ្នាំ ទៅ 22 ឆ្នាំ។

គោលបំណងរបស់នីតិបញ្ញត្តិនេះគឺដើម្បីធានាថាឪពុកម្តាយ អាណាព្យាបាល និងក្រុមគ្រួសាររបស់សិស្ស និងមនុស្សវ័យជំទង់ដែលមានពិការភាពអាចទទួលបាននូវព័ត៌មានសុក្រឹតត្រឹមត្រូវ ការបណ្តុះបណ្តាលជំនាញ និងការគាំទ្រពីមិត្តរួមថ្នាក់។ FECs មានគោលបំណងជួយឪពុកម្តាយឱ្យយល់កាន់តែច្បាស់ពីតម្រូវការអប់រំ និងការអភិវឌ្ឍន៍របស់កូនពួកគេ ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយអ្នកផ្តល់សេវាកម្ម ការបម្រើជាធនធានសម្រាប់ដំណើរការផែនការអប់រំជាបុគ្គល ចូលរួមក្នុងសកម្មភាពកំណែទម្រង់ និងកែលម្អសាលារៀន លើកកម្ពស់ជម្រើសក្នុងការដោះស្រាយវិវាទ និងគាំទ្រទៅលើទំនាក់ទំនងជាវិជ្ជមានរវាងឪពុកម្តាយសិស្ស និងអ្នកជំនាញ។ សេវាកម្មផ្តល់ជូនតាមរយៈ FEC នីមួយៗមានការប្រែប្រួលដោយអាស្រ័យទៅលើតម្រូវការរបស់សហគមន៍ជាក់ស្តែង។

### ព័ត៌មានទំនាក់ទំនង និងសេវាកម្មរបស់ FEC

ដើម្បីស្វែងរក FEC ដែលបម្រើសេវាកម្មជូនខោនធីរបស់អ្នក ឬ ហ្ស៊ីបកូដសម្រាប់មណ្ឌលសិក្សាធិការរួបរួម ទីក្រុង Los Angeles "Unified School District" (USD) សូមមើលតារាងខាងក្រោមដែលត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយ នៅក្នុងខែមីនា ឆ្នាំ 2024។

សម្រាប់ព័ត៌មានទំនាក់ទំនង FEC បច្ចុប្បន្នបំផុត សូមចូលទៅកាន់គេហទំព័រ CDE, អង្គការមាតាបិតាសម្រាប់ការអប់រំពិសេសរដ្ឋកាលីហ្វ័រញ៉ា "Special Education California Parent Organizations" នៅ https://www.cde.ca.gov/sp/se/qa/caprntorg.asp។

| អង្គការ | ខោនធីដែលបានបម្រើសេវាកម្មជូន | គេហទំព័រ |
|---|---|---|
| មជ្ឈមណ្ឌលធនធានគ្រួសារ លើមាគ៌ាបណ្តុះបណ្តាលសមត្ថភាព នៃខោនធី San Mateo "Ability Path's Family Resource Center of San Mateo County" | San Mateo | https://www.smcfrc.org/ |
| មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាចគ្រួសារ Alpha "Alpha Family Empowerment Center" | Santa Barbara | https://alphasb.org/ |
| អង្គការ បណ្តាញថែទាំមាតាបិតា "Care Parent Network" | Contra Costa | https://www.careparentnetwork.org/ |
| មជ្ឈមណ្ឌលពង្រឹងធនធានគ្រួសារដែលមានការប្រឈម "Challenged Family Resource Empowerment Center" | Merced | http://www.challengedfrc.org/ |
| ជំនោរការផ្លាស់ប្តូរសេវាកម្មគ្រួសារ "Changing Tides Family Services" | Humboldt | https://www.changingtidesfs.org/ |

| **អង្គការ** | **ខោនធីដែលបានបម្រើសេវាកម្មជូន** | **គេហទំព័រ** |
|---|---|---|
| បណ្ដាញធនធានគ្រួសារសម្រាប់មត្តេយ្យសិក្សា និងមជ្ឈមណ្ឌលពង្រឹងអំណាចគ្រួសារ "Early Start Family Resource Network and Family Empowerment Center" | Riverside, San Bernardino | www.esfrn.org |
| មជ្ឈមណ្ឌលធនធានគ្រួសារពិសេស "Exceptional Family Resource Center" (EFRC) | Imperial, San Diego | https://efrconline.org/ |
| អង្គភាពគ្មានដែនកំណត់សម្រាប់ឪពុកម្ដាយដែលមានតម្រូវការពិសេស "Exceptional Parents Unlimited" (EPU) | Fresno, Kings, Madera, Mariposa | https://www.epuchildren.org/ |

| **អង្គការ** | **ខោនធីដែលបានបម្រើសេវាកម្មជូន** | **គេហទំព័រ** |
|---|---|---|
| មជ្ឈមណ្ឌលធនធាន និងការផ្តល់សិទ្ធិអំណាចផ្តោតលើគ្រួសារ "Family Focus Resource and Empowerment Center" | **ទីក្រុង Los Angeles - (តំបន់ច្រាំងទន្លេ A) រួមទាំង តំបន់ LEA និង ហ្ស៊ីបកូដខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម Acton-Agua Dulce USD, មណ្ឌលសិក្សាធិការថ្នាក់វិទ្យាល័យ Antelope Valley Union High SD, មណ្ឌលសិក្សាធិការ Castaic Union SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Eastside Union Elementary SD, មណ្ឌលសិក្សាធិការ Gorman Joint SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Hughes-Elizabeth Lakes Elementary SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Keppel Union Elementary SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Lancaster Elementary SD, មណ្ឌលសិក្សាធិការរួបរួម Las Virgenes USD, មណ្ឌលសិក្សាធិការ Newhall SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Palmdale Elementary SD, មណ្ឌលសិក្សាធិការ Saugus Union SD, SBE - Academia Avance Charter, មណ្ឌលសិក្សាធិការ Sulphur Springs Union SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Westside Union Elementary SD, មណ្ឌលសិក្សាធិការថ្នាក់វិទ្យាល័យ William S. Hart Union High SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Wilsona Elementary SD **ហ្ស៊ីបកូដ ទីក្រុង Los Angeles របស់ សាលារួបរួម (USD)៖** 90290, 91040, 91042, 91303, 91304, 91306, 91307, 91311, 91316, 91324, 91325, 91326, 91330, 91331, 91335, 91340, 91342, 91343, 91344, 91345, 91352, 91356, 91364, 91367, 91371, 91401, 91402, 91403, 91405, 91406, 91411, 91423, 91436, 91601, 91602, 91604, 91605, 91606, 91607, 91608 | https://csun.edu/family-focus-resource-center |

| អង្គការ | ខោនធីដែលបានបម្រើសេវាកម្មជូន | គេហទំព័រ |
|---|---|---|
| មជ្ឈមណ្ឌលធនធានគ្រួសារនៃ Redwoods "Family Resource Center of the Redwoods" | Del Norte | www.frcredwoods.org |
| អ្នកស្វែងរកធនធានគ្រួសារ "Family Resource Navigators" | Alameda | https://familyresourcenavigators.org/ |
| បណ្ដាញធនធានគ្រួសារ "Family Resource Network" | Amador, Calaveras, San Joaquin, Stanislaus, Tuolumne | https://www.frcn.org/ |
| អង្គការ Family SOUP | Colusa, Sutter, Yuba | http://www.familysoup.org/ |
| មជ្ឈមណ្ឌលធនធានគ្រួសារនៃក្ដីស្រលាញ់ H.E.A.R.T.S. និងមជ្ឈមណ្ឌលផ្ដល់សិទ្ធិអំណាច "H.E.A.R.T.S. Connection Family Resource Center and Empowerment Center" | Kern, Inyo, Mono | http://www.heartsfrc.org/ |
| មជ្ឈមណ្ឌលធនធានគ្រួសារ Lake - មជ្ឈមណ្ឌលផ្ដល់សិទ្ធិអំណាចគ្រួសារ "Lake Family Resource Center– Family Empowerment Center" | Lake | www.lakefrc.org |

| **អង្គការ** | **ខោនធីដែលបានបម្រើសេវាកម្មជូន** | **គេហទំព័រ** |
|---|---|---|
| បណ្តាញឪពុកម្តាយម៉ាទ្រីស និងមជ្ឈមណ្ឌលធនធាន "Matrix Parent Network & Resource Center" | Marin, Napa, Solano, Sonoma | https://www.matrixparents.org/ |
| ឪពុកម្តាយជួយឪពុកម្តាយ, Inc. "Parents Helping Parents, Inc." | Santa Clara | https://www.php.com/ |
| ឪពុកម្តាយជួយឪពុកម្តាយ San Luis Obispo "Parents Helping Parents San Luis Obispo" | San Luis Obispo | http://www.phpslo.org/ |
| មជ្ឈមណ្ឌលធនធានគ្រួសារ បណ្តាញមាតាបិតា Visalia "Parenting Network Visalia Family Resource Center" | Tulare | https://www.parentingnetwork.org/ |

| អង្គការ | ខោនធីដែលបានបម្រើសេវាកម្មជូន | គេហទំព័រ |
|---|---|---|
| មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាច និង ធនធានគ្រួសារសម្រាប់ឪពុកម្តាយ "Parents' Place Family Resource and Empowerment Center" | **ទីក្រុង Los Angeles-(តំបន់ច្រាំងទន្លេ J) រួមទាំង តំបន់ LEA ដូចខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម Arcadia USD, មណ្ឌលសិក្សាធិការរួបរួម Azusa USD, មណ្ឌលសិក្សាធិការរួបរួម Baldwin Park USD, មណ្ឌលសិក្សាធិការរួបរួម Bassett USD, មណ្ឌលសិក្សាធិការរួបរួម Bonita USD, មណ្ឌលសិក្សាធិការរួបរួម Charter Oak USD, មណ្ឌលសិក្សាធិការរួបរួម Claremont USD, មណ្ឌលសិក្សាធិការរួបរួម Covina Valley USD, មណ្ឌលសិក្សាធិការរួបរួម Duarte USD, មណ្ឌលសិក្សាធិការ El Monte City SD, មណ្ឌលសិក្សាធិការថ្នាក់វិទ្យាល័យ El Monte Union High SD, មណ្ឌលសិក្សាធិការរួបរួម Glendora USD, មណ្ឌលសិក្សាធិការរួបរួម Hacienda La Puente USD, មណ្ឌលសិក្សាធិការរួបរួម Monrovia USD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Mountain View Elementary SD, មណ្ឌលសិក្សាធិការរួបរួម Pasadena USD, មណ្ឌលសិក្សាធិការរួបរួម Pomona USD, មណ្ឌលសិក្សាធិការរួបរួម Rowland USD, មណ្ឌលសិក្សាធិការរួបរួម Valle Lindo USD, មណ្ឌលសិក្សាធិការរួបរួម Walnut Valley USD, មណ្ឌលសិក្សាធិការរួបរួម West Covina USD | http://www.parentsplacefrc.com/ |

| **អង្គការ** | **ខោនធីដែលបានបម្រើសេវាកម្មជូន** | **គេហទំព័រ** |
|---|---|---|
| មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាចគ្រួសារក្នុងភាពជាដៃគូ "Partnership Family Empowerment Center" | **ទីក្រុង Los Angeles-(តំបន់ច្រាំងទន្លេ J) រួមទាំង តំបន់ LEA និង ហ្ស៊ីប កូដ ដូចខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម Alhambra USD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា East Whittier Elementary SD, មណ្ឌលសិក្សាធិការរួបរួម El Rancho USD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Garvey Elementary SD, មណ្ឌលសិក្សាធិការ Los Nietos SD, មណ្ឌលសិក្សាធិការរួបរួម Montebello USD, មណ្ឌលសិក្សាធិការរួបរួម Rosemead USD, មណ្ឌលសិក្សាធិការរួបរួម San Gabriel USD, មណ្ឌលសិក្សាធិការរួបរួម San Marino USD, សាលាត្រៀមមហាវិទ្យាល័យ SBE - Los Angeles College Prep Academy, មណ្ឌលសិក្សាធិការរួបរួម South Pasadena USD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា South Whittier Elementary SD, មណ្ឌលសិក្សាធិការ Temple City SD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Whittier City Elementary SD, មណ្ឌលសិក្សាធិការថ្នាក់វិទ្យាល័យ Whittier Union High SD **ហ្ស៊ីបបកូដ ទីក្រុង Los Angeles របស់មណ្ឌលសិក្សាធិការរួបរួម (USD)៖** 90022, 90023, 90031, 90032, 90033, 90040, 90041, 90042, 90063, 90065, 91754 | http://www.eastlapartnershipfec.net |
| អង្គការសេវាកម្មជនបទ Plumas "Plumas Rural Services" | Lassen, Modoc, Plumas, Sierra | https://www.plumasruralservices.org/ |
| អង្គការ Rainbow Connection Family Resource and Empowerment Center | Ventura | https://rainbowconnectionfrc.weebly.com/ |

| **អង្គការ** | **ខោនធីដែលបានបម្រើសេវាកម្មជូន** | **គេហទំព័រ** |
|---|---|---|
| មជ្ឈមណ្ឌលធនធានគ្រួសារ Raise & Shine Early Start "Raise & Shine Early Start Family Resource Center" | Mendocino | https://www.raiseandshine.org/ |
| អង្គការផ្តល់សិទ្ធិអំណាចគ្រួសារ Rowell នៃរដ្ឋកាលីហ្វ័រញ៉ាខាងជើង "Rowell Family Empowerment of Northern California" | Butte, Glenn, Shasta, Siskiyou, Tehama, Trinity | https://rfenc.org |
| មជ្ឈមណ្ឌលតំបន់ South Central Los Angeles (មជ្ឈមណ្ឌលធនធានគ្រួសារ McClaney) "South Central Los Angeles Regional Center (McClaney Family Resource Center)" | **ទីក្រុង Los Angeles - (តំបន់ច្រាំងទន្លេ B) រួមទាំង តំបន់ LEA និង ហ្សីបកូដ ខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម Compton USD, មណ្ឌលសិក្សាធិការរួបរួម Downey USD, មណ្ឌលសិក្សាធិការរួបរួម Lynwood USD, មណ្ឌលសិក្សាធិការរួបរួម Paramount USD **ហ្សីបកូដ ទីក្រុង Los Angeles របស់មណ្ឌលសិក្សាធិការរួបរួម (USD)៖** 90001, 90002, 90003, 90007, 90008, 90011, 90016, 90018, 90037, 90043, 90044, 90047, 90058, 90059, 90061, 90062, 90201, 90255, 90270, 90280 | https://sclarc.org/ |
| អង្គការតភ្ជាប់កុមារដែលមានតម្រូវការពិសេស "Special Kids Connect" | Monterey | https://specialkidsconnect.org/ |

| អង្គការ | ខោនធីដែលបានបម្រើសេវាកម្មជូន | គេហទំព័រ |
|---|---|---|
| អង្គការបណ្ដាញព័ត៌មានមាតាបិតាពិសេស (SPIN) "Special Parents Information Network (SPIN)" | San Benito, Santa Cruz | https://www.spinsc.org/ |
| អង្គការជំនួយគ្រួសារកុមារពិការ "Support for Families of Children with Disabilities" | San Francisco | https://www.supportforfamilies.org/ |
| អង្គការក្រុមការងារអ្នកតស៊ូមតិសម្រាប់កុមារដែលមានតម្រូវការពិសេស, Inc. (TASK) "Team of Advocates for Special Kids, Inc. (TASK)" | Orange | https://taskca.org/ |

| | | |
|---|---|---|
| អង្គការ ក្រុមការងារអ្នកតស៊ូមតិសម្រាប់កុមារដែលមានតម្រូវការពិសេស, Inc. (TASK) "Team of Advocates for Special Kids, Inc. (TASK)" | **ទីក្រុង Los Angeles - (តំបន់ច្រាំងទន្លេ E) រួមទាំង តំបន់ LEA និង ហ្ស៊ីបកូដ ខាងក្រោម៖** មណ្ឌលសិក្សាធិការ Hermosa Beach City SD, មណ្ឌលសិក្សាធិការរួបរួម Manhattan Beach USD, មណ្ឌលសិក្សាធិការរួបរួម Palos Verdes Peninsula USD, មណ្ឌលសិក្សាធិការរួបរួម Redondo Beach USD, មណ្ឌលសិក្សាធិការរួបរួមTorrance USD **ហ្ស៊ីបបកូដ ទីក្រុង Los Angeles របស់ មណ្ឌលសិក្សាធិការរួបរួម (USD)៖** 90275, 90501, 90502<br><br>**ទីក្រុង Los Angeles- (តំបន់ច្រាំងទន្លេ F) រួមទាំង តំបន់ LEA និងហ្ស៊ីប កូដ ដូចខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម Long Beach USD<br><br>**ទីក្រុង Los Angeles- (តំបន់ច្រាំងទន្លេ G) រួមទាំង តំបន់ LEA និង ហ្ស៊ីប កូដ ដូចខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម ABC USD, មណ្ឌលសិក្សាធិការរួបរួម Bellflower USD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Little Lake City Elementary SD, សាលា Norwalk La Mirada<br><br>**ទីក្រុង Los Angeles- (តំបន់ច្រាំងទន្លេ H) រួមទាំង ហ្ស៊ីបកូដ ដូចខាងក្រោម៖ ហ្ស៊ីបបកូដ ទីក្រុង Los Angeles របស់ មណ្ឌលសិក្សាធិការរួបរួម (USD)៖** 90710, 90717, 90731, 90732, 90744, 90745, 90746, 90810 | https://taskca.org/ |

| **អង្គការ** | **ខោនធីដែលបានបម្រើសេវាកម្មជូន** | **គេហទំព័រ** |
|---|---|---|
| | **ទីក្រុង Los Angeles- (តំបន់ច្រាំងទន្លេ I) រួមទាំង តំបន់ LEA និង ហ្ស៊ីប កូដ ដូចខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម Burbank USD, មណ្ឌលសិក្សាធិការរួបរួម Glendale USD, មណ្ឌលសិក្សាធិការរួបរួម La Cañada USD **ហ្ស៊ីបកូដ ទីក្រុង Los Angeles របស់ មណ្ឌលសិក្សាធិការរួបរួម (USD)៖** 90004, 90005, 90006, 90010, 90012, 90013, 90014, 90015, 90017, 90019, 90020, 90021, 90026, 90027, 90028, 90029, 90035, 90036, 90038, 90039, 90046, 90048, 90057, 90068, 90069, 90071 | |
| WarmLine Family Resource Center | Alpine, El Dorado, Nevada, Placer, Sacramento, Yolo | http://www.warmlinefrc.org/ |
| មជ្ឈមណ្ឌលធនធានគ្រួសារ និងផ្តល់សិទ្ធិអំណាចភាគខាងលិច "Westside Family Resource and Empowerment Center" | **ទីក្រុង Los Angeles- (តំបន់ច្រាំងទន្លេ D) រួមទាំង តំបន់ LEA និងហ្ស៊ីប កូដ ដូចខាងក្រោម៖** មណ្ឌលសិក្សាធិការរួបរួម Beverly Hills USD, មណ្ឌលសិក្សាធិការថ្នាក់វិទ្យាល័យ Centinela Valley Union High SD, មណ្ឌលសិក្សាធិការរួបរួម Culver City USD, មណ្ឌលសិក្សាធិការរួបរួម El Segundo USD, មណ្ឌលសិក្សាធិការ Hawthorne SD, មណ្ឌលសិក្សាធិការរួបរួម Inglewood USD, មណ្ឌលសិក្សាធិការថ្នាក់បឋមសិក្សា Lawndale Elementary SD, មណ្ឌលសិក្សាធិការ Lennox SD, មណ្ឌលសិក្សាធិការរួបរួម Santa Monica-Malibu USD, SBE - New West Charter, មណ្ឌលសិក្សាធិការរួបរួម Wiseburn USD **ហ្ស៊ីបកូដ ទីក្រុង Los Angeles របស់ មណ្ឌលសិក្សាធិការរួបរួម (USD)៖** 90024, 90025, 90034, 90035, 90045, 90049, 90064, 90066, 90067, 90077, 90094, 90210, 90230, 90247, 90248, 90249, 90272, 90291, 90292, 90293, 90301, 90303 | http://wfrec.org/ |

## សទ្ទានុក្រមនៃអក្សរកាត់ដែលប្រើនៅក្នុងសេចក្តីជូនដំណឹងនេះ

ADR៖ ជម្រើសក្នុងការដោះស្រាយវិវាទ "Alternative Dispute Resolution"

*CFR៖ ច្បាប់នៃបទប្បញ្ញត្តិសហព័ន្ធ "Code of Federal Regulations"*

*EC*៖ ច្បាប់អប់រំរដ្ឋកាលីហ្វ័រញ៉ា "California *Education Code"*

FAPE: ការអប់រំសមស្របសម្រាប់គ្រប់គ្នាដោយឥតគិតថ្លៃ "Free Appropriate Public Education"

FEC៖ មជ្ឈមណ្ឌលផ្តល់សិទ្ធិអំណាចគ្រួសារស្តីពីពិការភាព "Family Empowerment Center on Disability"

IDEA៖ ច្បាប់ស្តីពីការអប់រំជនពិការ "Individuals with Disabilities Education Act"

IEP៖ កម្មវិធីអប់រំជាបុគ្គល "Individualized Education Program"

PTIC៖ មជ្ឈមណ្ឌលព័ត៍មាន និងបណ្តុះបណ្តាលមាតាបិតាសិស្ស "Parent Training and Information Center"

OAH៖ ការិយាល័យសវនាការរដ្ឋបាល "Office of Administrative Hearings"

SELPA៖ តំបន់ផែនការអប់រំពិសេសក្នុងមូលដ្ឋាន "Special Education Local Plan Area"

*USC៖ ច្បាប់សហរដ្ឋអាមេរិក "United States Code"*